## ១-សេចក្តីផ្តើម

តាមទស្សនៈពុទ្ធសាសនា អាពាហ៍ពិពាហ៍មិនមែនឧត្តម ទាំងមិនមែនថាមិនឧត្តមដែរ។ ពុទ្ធសាសនាមិនបានចាត់ទុក អាពាហ៍ពិពាហ៍ថាជាកាតព្វកិច្ចរបស់សាសនា ទាំងមិនថាជាការប្រសិទ្ធិ ដែលរៀបចំឡើងក្នុងស្ថានសួគ៌ក៏ទេដែរ។ មនុស្សដែលមើលឃើញតែអាក្រក់បាននិយាយយ៉ាងដូច្នេះ ឯមនុស្សមួយចំនួនមានជំនឿថាអាពាហ៍ពិពាហ៍ គឺស្ថិតនៅក្នុងស្ថានសួគ៌ ហើយមានអ្នកខ្លះទៀតនិយាយថា វាត្រូវបានកត់ត្រាទុកនៅក្នុងស្ថាននរកផងដែរ។ ជាមូលដ្ឋាន! អាពាហ៍ពិពាហ៍ជាកាតព្វកិច្ចបុគ្គលផ្ទាល់ខ្លួននិងសង្គម វាមិនមែនជាការដាក់កំហិតនោះទេ។ បុរសស្ត្រីត្រូវតែមានសិទ្ធិសេរីភាពក្នុងការរៀបការ ឬក៏នៅលីវបាន។ រឿងនេះមិនបានមានន័យថាពុទ្ធសាសនាប្រឆាំងនឹងអាពាហ៍ពិពាហ៍នោះទេ គ្មាននរណាម្នាក់ក្នុងលោកនេះអាចនិយាយថាអាពាហ៍ពិពាហ៍អាក្រក់ ហើយក៏គ្មានសាសនាណាមួយប្រឆាំងនឹងអាពាហ៍ពិពាហ៍នេះដែរ។

ជាក់ស្តែង សព្វសត្វទាំងអស់កើតមកជាផលនៃជីវិតភេទសម្ពន្ធ។ បណ្តាមនុស្សទាំងឡាយ ស្ថាប័នអាពាហ៍ពិពាហ៍បានកើតឡើងដើម្បីឱ្យសង្គមធានាបាននូវការបន្តពូជពង្សមនុស្សជាតិឱ្យស្ថិតស្ថេរ ហើយធានាចំពោះការយកចិត្តទុកដាក់ទៅលើក្មេងៗ។ ការណ៍នេះស្ថិតនៅលើការ

ជដែកថាកុមារទាំងឡាយកើតឡើងតាមរយៈសេចក្តីសប្បាយ គឺការមានទំនាក់ទំនងផ្លូវភេទ ត្រូវតែទទួលខុសត្រូវចំពោះដៃគូពាក់ព័ន្ធ ដោយហោចទៅរហូតដល់ពួកគេមានការធំធាត់។ អាពាហ៍ពិពាហ៍ធានាថាការទទួលខុសត្រូវនេះគឺត្រូវតែលើកកំពស់និងអនុវត្ត។

សង្គមមួយលូតលាស់ទៅបាន តាមរយៈបណ្តាញនៃទំនាក់ទំនងដែលស្អិតរមួត គឺចេះយោគយល់គ្នា និងពឹងពាក់គ្នាទៅវិញទៅមក។ រាល់ទំនាក់ទំនងទាំងអស់ គឺជាការប្រព្រឹត្តចេញពីដួងចិត្តសុទ្ធសាធ ដើម្បីឧបត្ថម្ភគាំទ្រ និងការពារអ្នកដទៃ ក្នុងក្រុមមួយឬក្នុងសហគមន៍មួយ។ អាពាហ៍ពិពាហ៍ដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងនូវបណ្តាញទំនាក់ទំនង នៃការផ្តល់ការឧបត្ថម្ភគាំទ្រ និងការការពារនោះ។ អាពាហ៍ពិពាហ៍ដែលល្អធំធាត់និងចម្រើនឡើងជាលំដាប់ គឺកើតចេញពីការយោគយល់គ្នា មិនមែនជាការបង្ខិតបង្ខំនោះទេ គឺកើតចេញពីភក្តីភាពពិតៗ មិនត្រឹមតែលាយឡំទៅដោយភាពត្រេកត្រអាលប៉ុណ្ណោះទេ។ ស្ថាប័នអាពាហ៍ពិពាហ៍បានផ្តល់នូវមូលដ្ឋានយ៉ាងល្អប្រណីត សម្រាប់ការរីកចម្រើនវប្បធម៌នៃការសេពគប់របស់បុគ្គលពីរនាក់ ដែលពោរពេញដោយភាពរីករាយ ដើម្បីបណ្តុះឱ្យមានឡើង ឬដើម្បីកំចាត់បង់នូវភាពឯកោ បំពេញនូវភាពខ្វះខាតនិងសេចក្តីភ័យខ្លាច។ នៅក្នុងជីវិតអាពាហ៍ពិពាហ៍ ដៃគូនីមួយៗបង្កើតនូវមុខនាទីឱ្យបរិបូណ៌ ផ្តល់កម្លាំងចិត្ត និងភាពក្លាហានដល់គ្នានឹងគ្នា សម្តែង

នូវការគាំទ្រ និងកោតសរសើរ ទទួលស្គាល់នូវជំនាញម្នាក់ទៀតក្នុងការថែរក្សានិងផ្គត់ផ្គង់គ្រួសារ។ មិនត្រូវមានគំនិតថា បុរសខ្ពង់ខ្ពស់ជាងស្ត្រីឬស្ត្រីខ្ពង់ខ្ពស់ជាងបុរសឡើយ។ ម្នាក់ៗត្រូវបំពេញចំណុចខ្វះខាតឱ្យគ្នាទៅវិញទៅមក។ អាពាហ៍ពិពាហ៍គឺជាដៃគូដ៏ស្មើមុខស្មើមាត់ ភាពទន់ភ្លន់ប្រកបដោយចិត្តសប្បុរស ភាពស្ងប់ស្ងាត់ និងការបូជា (លះបង់)។

ក្នុងពុទ្ធសាសនា បុគ្គលអាចស្វែងរកឱវាទដ៏ចាំបាច់ទាំងអស់ ដែលអាចជួយអ្នកនោះ នាំទៅរកសុភមង្គលជីវិតអាពាហ៍ពិពាហ៍បាន។ បុគ្គលពុំគប្បីព្រងើយកន្តើយចំពោះឱវាទ ដែលទូន្មានដោយព្រះសម្មាសម្ពុទ្ធឡើយ ប្រសិនបើគាត់ពិតជាចង់ដឹកនាំជីវិតអាពាហ៍ពិពាហ៍ ឱ្យប្រកបដោយសុភ-មង្គលមែននោះ។ នៅក្នុងព្រះសូត្រទាំងឡាយរបស់ព្រះអង្គព្រះសម្មា-សម្ពុទ្ធបានត្រាស់សម្តែងនូវឱវាទផ្សេងៗ ចំពោះគូស្វាមីភរិយានិងចំពោះបុគ្គលដែលកំពុងគិតអំពីអាពាហ៍ពិពាហ៍។ ព្រះអង្គត្រាស់ថាៈ

ប្រសិនបុរសនិងនារី ស្មោះស្ម័គ្រទាំងពីរចង់រៀបការ
ត្រូវមើលចរិតនិងចរិយា ពិនិត្យចិន្តាឱ្យស្របគ្នា
ត្រូវចេះយោគយល់ផ្តល់គំនិត ចេះជួយចេះគិតមិនរុញរា
ពេលជួបឧបសគ្គរួមសាមគ្គា នោះទើបចាត់ជាមានសំណាង។

## ២.លក្ខណៈនៃសេចក្តីស្នេហា និងភាពសប្បាយរីករាយ

### *សេចក្តីស្នេហា*

មានប្រភេទនៃសេចក្តីស្នេហាផ្សេងៗគ្នា ហើយសេចក្តីស្នេហាទាំងនេះបញ្ជាក់ផ្សេងៗ ដូចជាសេចក្តីស្នេហារបស់មាតា សេចក្តីស្នេហារបស់បងប្អូនប្រុស សេចក្តីស្នេហាប្រកបទៅដោយភាពត្រេកត្រអាល សេចក្តីស្នេហាផ្អែកអារម្មណ៍ សេចក្តីស្នេហាប្រកបដោយកាមគុណ សេចក្តីស្នេហាប្រកបដោយភាពអាត្មានិយម សេចក្តីស្នេហាមិនប្រកបដោយភាពអាត្មានិយម និងសេចក្តីស្នេហាជាសាកល ( មេត្តា) ។

ប្រសិនបើមនុស្សបង្កើតតែសេចក្តីស្នេហាផ្អែករូបរាងកាយ ឬក៏សេចក្តីស្នេហាពោរពេញដោយភាពអាត្មានិយមចំពោះគ្នានឹងគ្នានោះ សេចក្តីស្នេហាប្រភេទនេះ នឹងមិនអាចស្ថិតស្ថេរនៅរយៈពេលយូរបានឡើយ ។ នៅក្នុងទំនាក់ទំនងស្នេហាពិត បុគ្គលពុំគប្បីសួរថាតើខ្លួនអាចទទួលបានប៉ុណ្ណា ប៉ុន្តែគួរសួរថាតើខ្លួនអាចផ្តល់ឱ្យបានប៉ុណ្ណាវិញទើបសម ។

កាលដែលសម្រស់ ពណ៌សម្បុរ និងយុវភាពចាប់ផ្តើមបាត់បង់បន្តិចម្តងៗ ប្តីដែលមានស្នេហាចំពោះតែរូបសម្បត្តិ អាចគិតនឹងរកនូវនារីវ័យក្មេងម្នាក់ទៀត ។ សេចក្តីស្នេហាប្រភេទនេះមានឈ្មោះថាជាសេចក្តី

ស្នេហារបស់សត្វធាតុ ឬសេចក្តីស្នេហាប្រកបដោយកាមរាគៈ។ ប្រសិនបើបុរសម្នាក់ ពិតជាបង្កើតនូវសេចក្តីស្នេហា ដែលជាការបញ្ជាក់នូវការយកចិត្តទុកដាក់របស់មនុស្សចំពោះដៃគូម្នាក់ទៀត បុរសនោះនឹងមិនផ្តោតការយកចិត្តទុកដាក់ ចំពោះតែសម្រស់ខាងក្រៅ និងភាពទាក់ទាញផ្នែករាងកាយរបស់ដៃគូខ្លួននោះទេ។ សម្រស់ និងភាពទាក់ទាញរបស់ដៃគូខ្លួនគប្បីស្ថិតនៅលើដួងចិត្ត ឬបេះដូង មិនមែនស្ថិតនៅលើអ្វីដែលខ្លួនមើលឃើញនោះទេ។ ដូចគ្នានេះដែរ ភរិយាដែលដើរតាមពុទ្ធឱវាទ នឹងមិនដែលព្រងើយកន្តើយចំពោះស្វាមីរបស់ខ្លួន បើទោះបីជាគាត់ឈានចូលវ័យចំណាស់ ក្រទ្រព្យសម្បត្តិ ឬមានជម្ងឺក៏ដោយ។

*"I have a fear that the modern girl loves to be Juliet to have a dozen Romeos. She loves adventure... The modern girl dresses not to protect herself from wind, rain and sun, but to attract attention. She improves upon nature by painting herself and looking extraordinary." - (Gandhi)*

*"ខ្ញុំមានការបារម្ភថា នារីសម័យទំនើប ចូលចិត្តធ្វើជា**ជូលៀត** ដែលមាន **រ៉ូមីអូ** ដល់ទៅមួយឡូ។ នាងចូលចិត្តផ្សងព្រេង... ។ នារីសម័យថ្មី ស្លៀកពាក់មិនមែន ដើម្បីការពារខ្លួនពីខ្យល់ ភ្លៀង និងកំដៅថ្ងៃឡើយ ប៉ុន្តែដើម្បីទាក់ទាញនូវការយកចិត្តទុកដាក់តែប៉ុណ្ណោះ។ នាងតុបតែង*

*ធម្មជាតិដោយការផាត់លំអខ្លួន ដើម្បីមើលទៅហាក់ដូចជាមិនធម្មតានោះទេ* ” ។ ( លោកមហាត្មៈគន្ធី)

## *ភេទសម្ព័ន្ធ*

ជាធម្មជាតិ ភេទសម្ព័ន្ធនោះមិនមែន ” អាក្រក់ ” ទេ ទោះបីជាចំណង់និងតណ្ហាចង់មានទំនាក់ទំនងផ្លូវភេទនោះ ជានិច្ចកាលតែងតែរំខានដល់សេចក្តីស្ងប់ផ្លូវចិត្ត និងមិនមិននាំមកនូវការរីកចម្រើនផ្នែកសតិបញ្ញាក៏ដោយ ។

នៅក្នុងស្ថានការណ៍ដ៏សមរម្យ ភេទសម្ព័ន្ធគឺជាការឡើងដល់ចំណុចខ្ពស់បំផុតនៃផ្នែករាងកាយ ចំពោះការបំពេញនូវទំនាក់ទំនងអារម្មណ៍ដ៏ជ្រាលជ្រៅ ដែលដៃគូទាំងពីរផ្តល់ឱ្យនិងចាប់យកស្មើគ្នា ។

ការពិពណ៌នាអំពីរូបភាពនៃសេចក្តីស្នេហាដោយក្រុមឈ្មួញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនៅក្នុងអ្វីដែលយើងហៅថា ***វប្បធម៌លោកខាងលិច*** មិនមែនជាសេចក្តីស្នេហាពិតឡើយ ។ កាលណាសត្វតិរច្ឆានចង់មានភេទសម្ព័ន្ធ វាបង្ហាញនូវក្តីស្រឡាញ់របស់វា ប៉ុន្តែក្រោយពីបានឆ្លងកាត់ការរួមសង្វាសហើយ វាក៏ភ្លេចនូវក្តីស្នេហានោះភ្លាម ពីព្រោះក្នុងសត្វតិរច្ឆាននោះ ការរួមសង្វាសគឺគ្រាន់តែជាការជំរុញតាមសភាវគតិចាំបាច់សម្រាប់

ជាតិកម្មប៉ុណ្ណោះ។ ប៉ុន្តែមនុស្សជាតិវិញ មានអ្វីៗជាច្រើនក្នុងការផ្តល់នូវវិភាគទានក្នុងទស្សនៈសេចក្តីស្នេហានេះ។ កាតព្វកិច្ចនិងការទទួលខុសត្រូវគឺជាគ្រឿងផ្សំយ៉ាងសំខាន់ សម្រាប់ការរក្សានូវឯកភាព ភាពសុខដុមរមនា និងការយោគយល់គ្នាក្នុងទំនាក់ទំនងរវាងមនុស្សជាតិ។

ភេទសម្ព័ន្ធ មិនមែនជាគ្រឿងផ្សំយ៉ាងសំខាន់សម្រាប់សេចក្តីសុខក្នុងជីវិតអាពាហ៍ពិពាហ៍នោះទេ។ បុគ្គលដែលបានក្លាយជាទាសៈក្នុងការរួមភេទអាចនឹងបំផ្លាញនូវសេចក្តីស្នេហា និងមនុស្សធម៌ក្នុងជីវិតអាពាហ៍-ពិពាហ៍។ ក្រៅពីនេះ ស្ត្រីត្រូវឈប់គិតថារូបនាងជាកម្មវត្ថុនៃកាមរាគៈរបស់បុរសទៀត។ ការបង្ការគឺស្ថិតនៅក្នុងដៃរបស់នារីច្រើនជាងក្នុងដៃបុរស។ ជាធម្មតានាងត្រូវតែកាត់បន្ថយការសំអិតសំអាងខ្លួន ដើម្បីធ្វើឱ្យបុរសរីករាយ សូម្បីតែបុរសនោះគឺជាប្តីរបស់នាងក៏ដោយ។ ប្រសិនបើនាងចង់បានជាដៃគូស្មើភាពជាមួយបុរស នាងគប្បីស្លៀកពាក់ដែលអាចឱ្យតម្លៃរបស់នាងត្រូវបានប្រសើរឡើង ហើយនាងមិនក្លាយជានិមិត្តរូបផ្លូវភេទឡើយ។ "*អាពាហ៍ពិពាហ៍សម្រាបបំពេញនូវភាពស្រេកឃ្លាននៃកាមគុណនោះ មិនមែនជាអាពាហ៍ពិពាហ៍ពិតប្រាកដឡើយ វាគឺជារាគតណ្ហាប៉ុណ្ណោះ*"។ (មហាត្មៈគន្ធី)

តាមពិតទៅ សេចក្តីស្នេហាអាចជាផលិតផលនៃភេទសម្ព័ន្ធ ប៉ុន្តែភេទសម្ព័ន្ធក៏អាចជាផលនៃសេចក្តីស្នេហាដែរគឺៈ ការមានភេទសម្ព័ន្ធគឺជាការបញ្ជាក់នូវសេចក្តីស្នេហា។ នៅក្នុងឧត្តមគតិនៃសុភមង្គលជីវិតអាពាហ៍ពិពាហ៍ ទាំងសេចក្តីស្នេហានិងការរួមភេទមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ។

## *ការពន្យល់របស់ព្រះសម្មាសម្ពុទ្ធ*

យើងអាចសិក្សាបាននូវព្រះពុទ្ធឱវាទ ទាក់ទងនឹងអារម្មណ៍ដែលបុរសស្ត្រីមានចំពោះគ្នានឹងគ្នា។ ព្រះសម្ពុទ្ធត្រាស់ថាព្រះអង្គមិនដែលបានឃើញអារម្មណ៍ណាមួយក្នុងលោកនេះ ដែលទាក់ទាញការយកចិត្តទុកដាក់របស់បុរសជាងរូបស្ត្រីនោះទេ។ ហើយទន្ទឹមគ្នានេះដែរចំណាប់អារម្មណ៍ដ៏ចំបងសម្រាប់ស្ត្រីនោះ គឺរូបបុរសនោះដែរ។ វាមានន័យថាតាមធម្មជាតិស្ត្រីនិងបុរសបានផ្តល់នូវសេចក្តីសុខជាលោកិយ៍ ឱ្យគ្នាទៅវិញទៅមកដោយពិត។ ពួកគេពុំអាចទទួលបាននូវសេចក្តីសុខប្រភេទនេះមកពីវត្ថុណាមួយផ្សេងទៀតបានឡើយ។ កាលណាយើងពិនិត្យយ៉ាងហ្មត់ចត់ យើងសម្គាល់ថាបណ្តាវត្ថុទាំងឡាយដែលផ្តល់នូវសេចក្តីសុខនោះ គឺគ្មានអារម្មណ៍ដទៃណា អាចធ្វើឱ្យបញ្ចវិញ្ញាណរីករាយក្នុងពេលតែមួយក្រៅពីរូបបុរសស្ត្រីនោះឡើយ។

ជនជាតិក្រិកសម័យបុរាណបានដឹងពីបញ្ហានេះ ពួកគេបាននិយាយថារូបបុរសនិងស្ត្រីគឺតែមួយពីកំណើត។ ពួកគេត្រូវបានបំបែក ហើយផ្នែកទាំងពីរដែលត្រូវបានបំបែកនោះ នៅតែស្វែងរកគ្នាជាប្រចាំ ដើម្បីរួបរួមគ្នាជារូបបុរសស្ត្រីឡើងវិញ។

## *ភាពរីករាយ*

យុវវ័យចូលចិត្តផ្តេកផ្តួលទៅតាមភាពត្រេកត្រអាលលោកីយ៍ ដែលរួមបញ្ចូលទាំងរឿងល្អ និងអាក្រក់។ រឿងល្អដូចជាការរីករាយនឹងបទភ្លេង ការតែងកំណាព្យ ការរាំរែក អាហារឆ្ងាញ់ៗ សម្លៀកបំពាក់ និងករណីស្រដៀងគ្នា ដែលមិនធ្វើឱ្យអន្តរាយដល់រាងកាយ។ តាមពិតរបស់ទាំងនេះ បានត្រឹមតែរារាំងយើង ពីការមើលឱ្យឃើញនូវធម្មជាតិ ដែលកំពុងប្រព្រឹត្ត ទៅនិងភាពមិនប្រាកដប្រជានៃអត្ថិភាពនេះប៉ុណ្ណោះ ហើយដោយហេតុនោះ គឺពន្យានូវសមត្ថភាពរបស់យើងមិនឱ្យដឹងនូវធម្មជាតិពិតនៃអនត្តា ពោលគឺមិនមែនតួខ្លួននោះឯង។

ឥន្ទ្រីយ៍[១] និងវិញ្ញាណរបស់យុវវ័យបរិសុទ្ធនិងវាងវៃណាស់ ពួកគេមានចំណង់យ៉ាងខ្លាំង ក្នុងការបំពេញនូវវិញ្ញាណទាំងប្រាំ។ ស្ទើរតែរាល់ថ្ងៃ

១. ឥន្ទ្រីយ៍សព្ទនេះ លោកសំដៅយកសភាវៈជាធំ បានដល់ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត។

ពួកគេមានគំរោង និងគិតរកផ្លូវនិងមធ្យោបាយដើម្បីបានពិសោធនូវភាពត្រេកត្រអាលខ្លះៗ។ ដោយធម្មជាតិនៃអត្ថិភាពសុទ្ធសាធ បុគ្គលនឹងមិនដែលបំពេញនូវចំណង់ពេញទាំងស្រុង ជាមួយនឹងភាពត្រេកត្រអាលចំពោះអ្វីៗដែលបុគ្គលបានឆ្លងកាត់នោះឡើយ ហើយជាលទ្ធផល តណ្ហានោះរឹតតែបង្កើតឱ្យមានភាពរសាប់រសល់ និងការព្រួយបារម្ភត្រឡប់មកវិញថែមទៀតតែប៉ុណ្ណោះ។

កាលដែលបុគ្គលឈប់ប្រាថ្នា ចំពោះភាពត្រេកត្រអាលផ្នែកកាមគុណ ហើយមិនស្វែងរកភាពស្រណុកសុខស្រួលផ្នែករាងកាយជាមួយអ្នកដទៃនោះ តម្រូវការសម្រាប់អាពាហ៍ពិពាហ៍ក៏មិនកើតឡើងឡើយ។ សេចក្តីទុក្ខ និងភាពរីករាយលោកីយ៍ ទាំងពីរគឺជាលទ្ធផលរបស់រាគតណ្ហាឧបាទាន និងអារម្មណ៍។ ប្រសិនបើយើងព្យាយាមគ្រប់គ្រង និងសង្កត់នូវអារម្មណ៍របស់យើង ដោយរក្សានូវមធ្យោបាយមិនប្រាកដនិយម យើងបង្កើតនូវភាពរំខានក្នុងចិត្ត និងក្នុងផ្នែករាងកាយរបស់យើងផងដែរ។ ដូច្នេះហើយយើងត្រូវដឹងពីរបៀបដោះស្រាយ និងគ្រប់គ្រងនូវរាគៈរបស់មនុស្ស។ បើគ្មានការភាន់ច្រឡំ និងការប្រើប្រាស់រាគៈនេះខុសទេ យើងគង់អាចអប់រំសង្កត់ចំណង់របស់យើងបានតាមរយៈបញ្ញាដ៏ត្រឹមត្រូវ។

# ៣-ភាពពិតនៃជីវិតអាពាហ៍ពិពាហ៍

លោក **ចនហ៏ ជេ រ៉ូបិនសុន** ក្នុងសៀវភៅរបស់លោកមានចំណង ជើងថា **"Of Suchness"** **"នៃការពិត"** បានផ្តល់ដំបូន្មានស្តីអំពីសេចក្តីស្នេហា ភេទសម្ព័ន្ធ និងជីវិតអាពាហ៍ពិពាហ៍ថា "ចូរប្រុងប្រយ័ត្ន និងចែកឱ្យដាច់ពីគ្នា វាជាការងាយស្រួលណាស់ ក្នុងការរៀបអាពាហ៍ពិពាហ៍ជាជាងមិនរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើអ្នកមានគូដ៏ត្រឹមត្រូវ វាគឺជាស្ថានសួគ៌ ហើយប្រសិនបើមិនដូច្នេះទេ អ្នកនឹងរស់នៅក្នុងស្ថាននរក ២៤ម៉ោងជារៀងរាល់ថ្ងៃ ដែលតោងជាប់នឹងអ្នកជានិច្ច វាក៏អាចជារឿងរ៉ាវដ៏ល្វីងជូរចត់បំផុតមួយក្នុងជីវិត។ ជីវិតនោះវាពិតជាចម្លែកណាស់ហើយ។ យ៉ាងណាក៏ដោយ កាលដែលបុគ្គលរកឃើញគូដ៏សមរម្យនោះ បុគ្គលដឹងវាយ៉ាងច្បាស់ដោយចិត្តរបស់ខ្លួន។ វាមិនមែនគ្រាន់តែជាការរំជើបរំជួលមួយខណៈៗនោះទេ ប៉ុន្តែការជំរុញនៃភេទដ៏មានឥទ្ធិពលបានរុញច្រានយុវវ័យឱ្យដាំដូងក្បាលចូលទៅក្នុងសកម្មភាពងងឹតងងល់ ហើយបុគ្គលមិនអាចទុកចិត្តចំពោះអារម្មណ៍របស់ខ្លួនខ្លាំងពេកនោះទេ ។ ជាពិសេសនោះ ជាការពិតណាស់ ប្រសិនបើបុគ្គលផឹកហើយវង្វេងឡប់សតិមែនទែននោះ សូម្បីតែស្រីចើកដ៏អាក្រក់បំផុតក្នុងបារងងឹត អាចមើលទៅដូចជាព្រះនាងកាមទេព ហើយសម្រស់របស់នាងក៏ក្លាយជារបស់ដែលមិនអាចនឹងអត់ទ្រាំបាន។ សេចក្តីស្នេហាគឺជាអ្វីៗដែលលើសពីការមាន

ទំនាក់ទំនងផ្លូវភេទទៅទៀត ទំនាក់ទំនងផ្លូវភេទនេះគឺជាគ្រឹះនៃជីវសាស្ត្រ រវាងបុរសស្ត្រីប៉ុណ្ណោះ។ សេចក្តីស្នេហានិងភេទសម្ព័ន្ធត្រូវត្បាញចូលគ្នា និងលាយឡំគ្នាទៅវិញទៅមក។

## *បញ្ហាទាំងឡាយ*

ស្ទើរតែរៀងរាល់ថ្ងៃ យើងតែងស្តាប់ឮមនុស្សម្នាត្អូញត្អែរអំពីអាពាហ៍ពិពាហ៍របស់ខ្លួន យើងពិតជាកម្របានឮរឿងរ៉ាវអំពីសុភមង្គលអាពាហ៍ពិពាហ៍ណាស់។ ពួកយុវវ័យទាំងឡាយអានសៀវភៅប្រលោម-លោកនិងមើលកុនបែបមនោសញ្ចេតនា ហើយសន្និដ្ឋានថាអាពាហ៍ពិពាហ៍គឺជាថ្នាលនៃផ្កាកូលាបដ៏ស្រស់ឆើត។ ជាអកុសលអាពាហ៍ពិពាហ៍មិនមែនផ្អែមដូចដែលយើងគិតនោះទេ។ អាពាហ៍ពិពាហ៍និងបញ្ហាជាច្រើនមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយមនុស្សទាំងឡាយត្រូវចងចាំថា កាលណាពួកគេរៀបការហើយ ពួកគេនឹងត្រូវប្រឈមមុខនឹងបញ្ហាទាំងឡាយនោះ ព្រមទាំងការទទួលខុសត្រូវ ដែលពួកគេមិនធ្លាប់បានរំពឹងទុកឬឆ្លងកាត់រហូតមកដល់ពេលនេះ។

មនុស្សតែងតែគិតថា វាជាកាតព្វកិច្ចត្រូវរៀបការ ហើយអាពាហ៍ពិពាហ៍គឺជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងជីវិតរបស់ខ្លួន ប៉ុន្តែដើម្បីធានា

បាននូវអាពាហ៍ពិពាហ៍មួយដែលជោគជ័យនោះ គូស្វាមីភរិយាត្រូវតែធ្វើឱ្យជីវិតរបស់ខ្លួនរស់នៅសុខដុមរមនា ដោយការកាត់បន្ថយឱ្យនៅសល់តិចបំផុតនូវអ្វីដែលខុសប្លែកគ្នាដែលមានក្នុងចន្លោះគូស្វាមីភរិយានោះ ។ បញ្ហាគ្រួសារបានញ៉ាំងមនុស្សដែលមើលឃើញតែពីអាក្រក់ ឱ្យនិយាយថាអាពាហ៍ពិពាហ៍ដែលប្រកបដោយសុខស្ងប់នោះ វាអាចកើតមានបានលុះត្រាតែអាពាហ៍ពិពាហ៍នោះមានរវាងភរិយាខ្វាក់និងស្វាមីថ្លង់ ពីព្រោះថាភរិយាខ្វាក់មិនអាចនឹងមើលឃើញកំហុសរបស់ស្វាមី ហើយស្វាមីថ្លង់នោះមិនអាចស្តាប់ឮពាក្យនិយាយច្រំដែល។ ពាក្យរអ៊ូរទាំរបស់ភរិយានោះបានដែរ ។

## *ការចែករំលែក និងភាពទុកចិត្ត*

បញ្ហាដ៏ចំបងមួយនៃបញ្ហាគ្រួសារ គឺការសង្ស័យ និងការមិនទុកចិត្តគ្នា ។ អាពាហ៍ពិពាហ៍គឺជាពរជ័យ ប៉ុន្តែមនុស្សជាច្រើនធ្វើឱ្យវាក្លាយជាបណ្តាសារ ដោយសារខ្វះការយល់ដឹង ។ ទាំងស្វាមីនិងភរិយាគួរគប្បីបង្ហាញនូវភាពទុកចិត្តដោយគ្មានមន្ទិលចំពោះគ្នាទៅវិញទៅមក ហើយចូរព្យាយាមកុំឱ្យមានអាថិកំបាំងរវាងគ្នានឹងគ្នាឡើយ ។ អាថិកំបាំងបង្កើតនូវការសង្ស័យ ការសង្ស័យនាំទៅរកការប្រច័ណ្ឌ ការប្រច័ណ្ឌបង្កជាកំហឹង

កំហឹងបណ្តាលឱ្យមានអរិភាព អរិភាពអាចបណ្តាលឱ្យមានការបែកបាក់គ្នា ការធ្វើអត្តឃាត ឬថែមទាំងធ្វើឃាតកម្មក៏សឹងមាន ។

ប្រសិនបើគូស្វាមីភរិយាមួយអាចចែករំលែកនូវសុខទុក្ខក្នុងជីវិតពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេអាចលួងលោម និងធ្វើឱ្យស្រាកស្រាន្តនូវសេចក្តីទុក្ខព្រួយរបស់គ្នាទៅវិញទៅមក ។ ដូច្នេះភរិយាឬស្វាមីនោះមិនគប្បីគិតរំពឹងតែភាពត្រេកត្រអាលប៉ុណ្ណោះទេ ។ វានឹងមានសេចក្តីទុក្ខសោកវេទនាយ៉ាងច្រើនក្រៃលែង ដែលពួកគេនឹងត្រូវប្រឈមមុខ ពួកគេត្រូវមានកម្លាំងឆន្ទៈ ដើម្បីកាត់បន្ថយនូវការលំបាក និងការមិនយល់ចិត្តគ្នា ។ ការជជែកគ្នាទៅវិញទៅមកអំពីបញ្ហាទាំងឡាយ នឹងផ្តល់ឱ្យពួកគេនូវភាពជឿជាក់ ដើម្បីរស់នៅជាមួយគ្នាប្រកបដោយការយោគយល់គ្នាខ្ពស់ ។

បុរសស្ត្រីត្រូវការភាពកក់ក្តៅចំពោះគ្នានឹងគ្នា កាលណាប្រឈមមុខនឹងបញ្ហានិងភាពលំបាកលំបិនទាំងឡាយ ។ អារម្មណ៍នៃភាពអសន្តិ-សុខនិងការរំជើបរំជួលនឹងរលាយបាត់អស់ ហើយជីវិតនឹងកាន់តែមានន័យឡើង មានសុភមង្គល ហើយមានចំណាប់អារម្មណ៍កាន់តែប្រសើរឡើង ប្រសិនបើមានដៃគូណាម្នាក់មានឆន្ទៈ ដើម្បីចែករំលែកនូវភារៈរបស់ដៃគូម្នាក់ទៀត ។

# ងងឹតងងល់ដោយអារម្មណ៍រំភើប

កាលបើបុគ្គលពីរនាក់ស្ថិតនៅក្នុងសេចក្ដីស្នេហា ពួកគេមានទំនោរក្នុងការបង្ហាញតែសភាពល្អ និងចរិតលក្ខណៈល្អៗតែប៉ុណ្ណោះចំពោះដៃគូ ដើម្បីបញ្ចាំងនូវចំណាប់អារម្មណ៍ល្អរបស់ពួកគេ។ សេចក្ដីស្នេហាត្រូវបានគេនិយាយថាខ្វាក់ ដូច្នេះហើយមនុស្សដែលស្ថិតនៅក្នុងសេចក្ដីស្នេហាមានទំនោរ ក្លាយជាភ្លេចភ្លាំងទាំងស្រុង ចំពោះគុណវិបត្តិពីធម្មជាតិរបស់គ្នាទៅវិញទៅមក។

ជាក់ស្ដែងម្នាក់ៗនឹងព្យាយាមដើម្បីធ្វើឱ្យលេចធ្លោនូវគុណសម្បត្តិរបស់ខ្លួនចំពោះម្នាក់ទៀត ហើយធ្វើឱ្យស្លុងក្នុងសេចក្ដីស្នេហា ពួកគេមានទំនោរទទួលគ្នានឹងគ្នានៅត្រឹមតែ "***តម្លៃមុខ***" ប៉ុណ្ណោះ។ គូស្នេហ៍នីមួយៗនឹងមិនបើកបង្ហាញនូវគុណវិបត្តិរបស់ខ្លួន ឬលក្ខណៈពិតរបស់ខ្លួនឡើយ ព្រោះខ្លាចបាត់បង់ដៃគូម្នាក់ទៀត។ គុណវិបត្តិផ្ទាល់ខ្លួនឯណានីមួយត្រូវបានបោសកប់លុបជាន់ទុកយ៉ាងស្ងាត់ នៅក្រោមកម្រាលព្រំ គឺថាធ្វើយ៉ាងនេះ ដើម្បីកុំឱ្យបាត់បង់នូវឱកាសនៃការយកឈ្នះគ្នាទៅវិញទៅមកនោះ។ មនុស្សដែលស្ថិតនៅក្នុងសេចក្ដីស្នេហា ក៏មាននិន្នាការធ្វើប្រងើយកន្ដើយចំពោះកំហុសឆ្គាំឆ្គងរបស់ដៃគូ ដោយគិតថាពួកគេនឹងអាចកែតម្រង់គ្នាបាននៅក្រោយពីរៀបការហើយ ឬថាពួកគេអាចនឹងរស់នៅជាមួយនឹង

កំហុសទាំងនេះបាន នោះហើយដែលយើងហៅថា "*ស្នេហានឹងមានជ័យជំនះលើអ្វីទាំងអស់*"។

ប៉ុន្តែក្រោយពីរៀបការហើយ អារម្មណ៍មនោសញ្ចេតនាគ្រាដំបូងក៏សឹករេចរឹល សភាពពិតនៃចរិតលក្ខណៈរបស់គ្នានឹងគ្នា នឹងត្រូវលាតត្រដាងឡើង។ បន្ទាប់មកសេចក្តីខកចិត្តយ៉ាងខ្លាំងរបស់បុគ្គលទាំងពីរ (ក៏កើតឡើង) ដូចជាមានពាក្យថា ស្បៃមុខដែលបានលាក់បាំងទុកជាយូរមកហើយ អារម្មណ៍ដែលចូលជ្រៅទៅយ៉ាងឆ្ងាយចំពោះគ្នានឹងគ្នានោះត្រូវរលុបបាត់ ដើម្បីសម្តែងនូវលក្ខណៈពិតនៃដៃគូទាំងពីរ បន្ទាប់មកការស្រងាកចិត្តយ៉ាងខ្លាំងក៏ចាប់ផ្តើមឡើង។

## *តម្រូវការផ្នែកសម្ភារៈ*

សេចក្តីស្នេហានោះ ពុំមានជីវិតដោយពឹងផ្អែកលើខ្យល់បរិសុទ្ធ ឬពន្លឺព្រះអាទិត្យតែម្យ៉ាងនោះទេ។ ពិភពលោកបច្ចុប្បន្ននេះគឺជាពិភពនៃសម្ភារនិយម ហើយដើម្បីបានបំពេញនូវតម្រូវការផ្នែកសម្ភារៈ ការមានបរិវត្ថុ និងថវិកាដ៏សមរម្យគឺជាខ្លឹមសារដ៏សំខាន់។ បើគ្មានរបស់ទាំងនេះហើយ គ្មានគ្រួសារណាអាចរស់នៅប្រកបដោយផាសុកភាពឡើយ។ ស្ថានភាពបែបនេះ ប្រហែលជាបង្ហាញនូវសុភាសិតថា "*កាល*

*ភាពក្រីក្រមកដល់មាត់ទ្វារ សេចក្តីស្នេហាក៏ហោះចេញតាមមាត់បង្អួច*"។ នេះមិនមែនមានន័យថា មនុស្សគ្រប់គ្នាត្រូវតែជាអ្នកមាន ដើម្បីធ្វើឱ្យជីវិតអាពាហ៍ពិពាហ៍ដំណើរការនោះទេ ប៉ុន្តែប្រសិនបើបុគ្គលមានភាពចាំបាច់នៃជីវិតដែលផ្តល់ឱ្យតាមរយៈការងារមានលំនឹង និងគម្រោងការណ៍យ៉ាងហ្មត់ចត់ ភាពព្រួយបារម្ភខុសទំនងជាច្រើននោះ ក៏អាចនឹងត្រូវកំចាត់បង់ចេញពីជីវិតអាពាហ៍ពិពាហ៍បានដែរ។

ភាពមិនស្រណុកសុខស្រួលនៃភាពក្រីក្រនោះ អាចនឹងចៀសវាងបាន ប្រសិនបើមានភាពយោគយល់រវាងគូស្វាមីភរិយាយ៉ាងពេញលេញ។ ដៃគូទាំងពីរត្រូវយល់ពីតម្លៃនៃការសន្តោស ទាំងពីរនាក់ត្រូវតែចាត់ទុករាល់បញ្ហាទាំងអស់ថាជា "បញ្ហារបស់យើង" ហើយចែករំលែកនូវវាសនាមិនទៀងទាត់ទាំងអស់នេះ ក្នុងស្មារតីពិតប្រាកដមួយនៃជីវិតដៃគូដ៏យូរអង្វែង។

## ឱវាទមុនអាពាហ៍ពិពាហ៍

នៅក្នុងគម្ពីរអង្គុត្តរនិកាយ មានផ្ទុកនូវឱវាទដ៏ប្រកបដោយគុណតម្លៃជាច្រើន ដែលព្រះសម្មាសម្ពុទ្ធបានត្រាស់សម្តែងដល់យុវនារីរៀបមុនអាពាហ៍ពិពាហ៍។ ដោយការដឹងថាវាអាចនឹងមានឧបសគ្គជាច្រើនជាមួយ

នឹងញាតិសាច់ថ្លៃ ទើបស្ត្រីទាំងឡាយត្រូវបានដាស់តឿនក្រើនរំលឹកឱ្យផ្តល់នូវការគោរពចំពោះម្តាយក្មេក ឪពុកក្មេក និងបម្រើពួកគាត់ដោយសេចក្តីស្រឡាញ់ដូចជាឪពុកម្តាយរបស់ខ្លួនបង្កើត។ ពួកនាងត្រូវបានរំពឹងថានឹងផ្តល់កិត្តិយសនិងការគោរពចំពោះសាច់ញាតិ និងមិត្តភក្តិរបស់ស្វាមី ដូច្នេះការបង្កើតនូវបរិយាកាស ដែលប្រកបដោយសេចក្តីសុខនិងភាព-ស្រុះស្រួលគ្នានៅក្នុងផ្ទះថ្មីរបស់ខ្លួន។

ពួកនាងក៏ត្រូវបានផ្តល់ឱវាទឱ្យសិក្សាឈ្វេងយល់ និងស្រាវជ្រាវអំពីលក្ខណៈរបស់ស្វាមីខ្លួនឱ្យដឹងពីសកម្មភាព ចរិតលក្ខណៈ និងអធ្យា-ស្រ័យដើម្បីឱ្យបានប្រយោជន៍ និងសហការគ្នាគ្រប់ពេលវេលាក្នុងផ្ទះថ្មីរបស់ខ្លួន។ ពួកនាងគប្បីសុភាពរាបសា មានសន្តានចិត្តល្អ និងមិនខ្ជះខ្ជាយប្រាក់ចំណូលរបស់ស្វាមី និងមើលការចំណាយក្នុងផ្ទះទាំងអស់ចាត់ចែងឱ្យបានត្រឹមត្រូវ។ ឱវាទរបស់ព្រះពុទ្ធអង្គជាង ២៥ សតវត្សរ៍កន្លងទៅហើយ នៅតែត្រឹមត្រូវ និងមានប្រយោជន៍រហូតមកដល់សព្វថ្ងៃនេះ។

## ៤.ទស្សនៈពុទ្ធសាសនា ស្តីអំពីអាពាហ៍ពិពាហ៍

ក្នុងទស្សនៈដែលបាននិយាយអំពី "*កំណើតនិងសេចក្តីទុក្ខ*" មនុស្សមួយចំនួនបានរិះគន់ព្រះពុទ្ធសាសនា ដោយនិយាយថាពុទ្ធសាសនាប្រឆាំងនឹងជីវិតអាពាហ៍ពិពាហ៍។ ពួកគេខុសទាំងស្រុងព្រះពុទ្ធមិនដែលបាននិយាយប្រឆាំងនឹងជីវិតអាពាហ៍ពិពាហ៍ឡើយ ប៉ុន្តែព្រះអង្គទ្រង់បានចង្អុលបង្ហាញនូវរាល់បញ្ហាភាពលំបាកលំបិន និងសេចក្តីព្រួយបារម្ភដែលមនុស្សទាំងឡាយអាចនឹងត្រូវប្រឈមមុខ នៅពេលដែលពួកគេចាប់យកនូវការទទួលខុសត្រូវនៃជីវិតអាពាហ៍ពិពាហ៍ មិនមែនដោយសារគ្រាន់តែព្រះអង្គក្រើនរំលឹកអំពីបញ្ហាក្នុងអាពាហ៍ពិពាហ៍ មានន័យថាព្រះសម្មាសម្ពុទ្ធមិនយល់ស្របនឹងជីវិតអាពាហ៍ពិពាហ៍នោះទេ។

សកម្មភាពនៃអាពាហ៍ពិពាហ៍បានបញ្ជាក់ថា បុគ្គលម្នាក់នៅតែប្រកាន់ជាប់ចំពោះរូបលោក ហើយដោយសារឥន្ទ្រីយ៍របស់យើងគ្របដណ្តប់ទៅដោយ*តណ្ហា* សេចក្តីប្រាថ្នា *ឧបាទាន* គឺសេចក្តីប្រកាន់មាំនិងអារម្មណ៍របស់មនុស្សជាតិ ប៉ុន្តែវាជាធម្មតាដែលបញ្ហាតែងតែនឹងកើតមានឡើង។ ការណ៍នេះកើតឡើងនៅពេលដែលយើងត្រូវពិចារណានូវតម្រូវការរបស់អ្នកដទៃ ហើយផ្តល់ឱ្យនូវអ្វីដែលអ្នកដទៃត្រូវការនោះ។

## ***តួនាទីសាសនា***

ការវិភាគយ៉ាងជ្រាលជ្រៅចំពោះលក្ខណៈនៃខ្លួន (អត្តលក្ខណៈ) មានសារៈសំខាន់ណាស់ ក្នុងការជួយយើងឱ្យយល់អំពីដើមកំណើតនៃបញ្ហា សេចក្តីព្រួយបារម្ភ សេចក្តីទុក្ខវេទនារបស់យើង និងពីរបៀបយកឈ្នះនូវបញ្ហាទាំងនោះ។ នៅក្នុងទីនេះឱវាទបែបសាសនាមានសារៈសំខាន់ណាស់ សម្រាប់រក្សានូវជីវិតប្រកបដោយសេចក្តីសុខស្ងប់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មនុស្សមិនគប្បីជាទាសៈរបស់សាសនាណាមួយឡើយ។ ***មនុស្សមិនមែនដើម្បីសាសនាទេ សាសនាទេតើដើម្បីមនុស្ស*** ។ មានន័យថា មនុស្សត្រូវដឹងពីរបៀបប្រើប្រាស់សាសនា សម្រាប់ធ្វើខ្លួនឱ្យប្រសើរឡើង និងសម្រាប់សេចក្តីសុខ ក្នុងមាគ៌ាដែលគួរឱ្យគោរពស្ងប់-ស្ងៃង។ ជាធម្មតាដោយការដើរតាមការសច្ចាបែបសាសនាជាក់លាក់ណាមួយ សិក្ខាបទ និងបទបញ្ញត្តិទាំងឡាយ ដែលប្រកបដោយសទ្ធាខ្វាក់ ឬដោយកម្លាំងបង្ខិតបង្ខំ ដោយគិតថាយើងមានកាតព្វកិច្ចត្រូវតែសមា-ទានកាន់យកនូវសិក្ខាបទនៃបទបញ្ញត្តិនោះៗ ហើយនឹងមិនចម្រើនដល់ការយល់ដឹងត្រឹមត្រូវនោះទេ។

ទស្សនៈដ៏សំខាន់មួយរបស់ពុទ្ធសាសនាគឺថា ព្រះពុទ្ធអង្គមិនបានដាក់កំហិតច្បាប់សាសនាណាមួយឡើយ។ ព្រះពុទ្ធអង្គគឺជាសាស្ត្រាចារ្យ

តែមួយគត់ដែលបានបញ្ញត្តិនូវក្រមវិន័យសម្រាប់ពួកយើង ដើម្បីលើកកំពស់ឱ្យស្របទៅតាមមាគ៌ាជីវិតរបស់យើងផ្ទាល់។ បុគ្គលអាចប្រតិបត្តិតាមសិក្ខាបទ សមាទាននូវសិក្ខាបទនោះៗដោយស្ម័គ្រចិត្ត ប៉ុន្តែវាមិនមែនជាច្បាប់សាសនា ដែលជាកាតព្វកិច្ចត្រូវតែធ្វើនោះទេ។ វាអាស្រ័យលើយើងទាំងស្រុងក្នុងការដើរតាមឱវាទនេះ តាមរយៈបញ្ញារបស់យើង និងពិសោធនូវអ្វីដែលល្អសម្រាប់ខ្លួនយើងផ្ទាល់ និងអ្នកដទៃផង។ តាមរយៈការវិនិច្ឆ័យ ចំណុចល្អនិងកំហុសនោះ យើងនឹងរៀនធ្វើតាមឱវាទដែលផ្តល់ឱ្យយើងតែសេចក្តីសុខសន្តិភាពម្យ៉ាងប៉ុណ្ណោះ។

បុគ្គលគប្បីព្យាយាមឈ្វេងយល់អំពីសភាពនៃជីវិតជាលោកីយ៍ ដោយការដឹងខ្លួនថា បុគ្គលនឹងត្រូវប្រឈមមុខចំពោះបញ្ហាទាំងឡាយ បុគ្គលនឹងអាចពង្រឹងនូវចិត្តរបស់ខ្លួន និងរៀបចំខ្លួនឱ្យបានច្រើនជាងនេះ ដើម្បីប្រឈមមុខចំពោះបញ្ហា ដែលអាចនឹងកើតមានឡើងនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ។ សាសនាមានសារៈសំខាន់ណាស់ក្នុងការជួយបុគ្គលឱ្យយកឈ្នះលើបញ្ហារបស់ខ្លួន។ អ្វីក៏ដោយដែលបុគ្គលបានសិក្សាអំពីគោលការណ៍សាសនា កាលដែលបុគ្គលនៅពីក្មេងអាចនឹងយកមកអនុវត្តដើម្បីចៀសវាងការយល់ច្រឡំ ការខកចិត្ត និងសេចក្តីអស់សង្ឃឹមបាន។ ទន្ទឹមគ្នានេះដែរ គុណសម្បត្តិល្អៗដ៏ជាក់លាក់ ដូចជាសេចក្តីអត់ធន់ និងបញ្ញាការយល់ដឹងដែលយើងបានសិក្សាតាមរយៈសាសនា គឺ

ជាទ្រព្យដ៏មានតម្លៃ និងមានសារៈសំខាន់ណាស់ ក្នុងការជួយយើងឱ្យដឹកនាំនូវជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសេចក្តីសុខសន្តិភាព ។

ជារឿងធម្មតា ដោយសារតែខ្វះការយោគយល់គ្នាទៅវិញទៅមកនេះហើយ ដែលដៃគូអាពាហ៍ពិពាហ៍ជាច្រើនដឹកនាំជីវិតដ៏ពោរពេញដោយសេចក្តីទុក្ខវេទនា ។ លទ្ធផលនេះគឺថាកូនៗដែលមិនដឹងអ្វីសោះក៏ត្រូវទទួលរងទុក្ខនេះដែរ ។ យើងគួរតែដឹងអំពីរបៀបដោះស្រាយបញ្ហារបស់ខ្លួនដើម្បីនឹងដឹកនាំជីវិតអាពាហ៍ពិពាហ៍ទៅរកសុភមង្គល ។ សាសនាអាចជួយអ្នកក្នុងបញ្ហានេះ ។

## ៥-ទ្វេគ្រោះបែបសាសនា

### *សិទ្ធិបុគ្គល*

បុព្វហេតុមួយបណ្តាបុព្វហេតុជាច្រើន នៃការព្រួយបារម្ភយ៉ាងក្រៃលែង ក្នុងចំណោមបុគ្គលដែលមិនបានស្ថិតនៅក្រោមសាសនាដែលមិនមែនជាជនជាតិសេមីទិចនោះ គឺជាបញ្ហានៃការផ្លាស់ប្តូរជំនឿសាសនាមុនពេលរៀបអាពាហ៍ពិពាហ៍។ ចំណែកឯពុទ្ធសាសនានិងសាសនាហិណ្ឌូមិនដែលតម្រូវឱ្យគូស្វាមីភរិយាកាន់សាសនាតែមួយដូចគ្នា មុនពេលរៀបចំអាពាហ៍ពិពាហ៍នោះទេ អីចឹងហើយទើបមានសាសនាជាច្រើនមាននិន្នាការចាប់យកផលប្រយោជន៍ពីភាពអត់ឱន និងសេរីភាពរបស់សាសនាទាំងនេះ។

ផ្ទុយនឹងអ្វីដែលប្រលោមលោកមនោសញ្ចេតនាជាច្រើនបាននិយាយ អាពាហ៍ពិពាហ៍មិនមែនមានន័យថា ជាការបាត់បង់នូវអត្ត-សញ្ញាណនៃបុគ្គលពីរនាក់ទាំងស្រុងនោះទេ។ នៅពេលដែលសាសនាមួយតម្រូវថាដៃគូទាំងពីរនាក់ត្រូវតែមានផ្លាកសញ្ញាសាសនាតែមួយដូចគ្នា វាបានច្រានចោលនូវសិទ្ធិមនុស្សនៃបុគ្គលម្នាក់ៗក្នុងការជឿលើអ្វីដែលបុគ្គលចង់ជឿ។ សង្គមទាំងឡាយក្នុងប្រវត្តិសាស្ត្របានបង្ហាញពី "*ឯកភាពក្នុង*

*ភាពបែកបាក់* ” គឺមិនមែនត្រឹមតែអាចធ្វើឡើងនោះទេ ប៉ុន្តែថែមទាំងគួរឱ្យប្រាថ្នាចង់បានទៀតផង ។ ចេញពីភាពបែកបាក់គ្នាចូលមករកការគោរពដ៏ក្រៃលែង និងភាពយោគយល់គ្នា ។ ការណ៏នេះគប្បីអនុវត្តនៅក្នុងអាពាហ៏ពិពាហ៏ផងដែរ ។ មានឧទាហរណ៏ជាក់ស្តែងជាច្រើនទូទាំងពិភព-លោកដែលស្វាមីភរិយារក្សានូវជំនឿរបស់ខ្លួនផ្ទាល់ ហើយនៅតែអាចរក្សានូវសុភមង្គលជីវិតអាពាហ៏ពិពាហ៏របស់ខ្លួនបាន ដោយមិនមានការប្រឈមមុខដាក់គ្នាឡើយ ។

ពុទ្ធសាសនិកជនទាំងឡាយ មិនបានជំទាស់ទៅនឹងអត្ថិភាពនៃលទ្ធិសាសនាដទៃទេនោះទេ សូម្បីតែស្ថិតនៅក្នុងផ្ទះតែមួយក៏ដោយ ។ ជាអកុសល ឥរិយាបថដ៏ប្រកបដោយសប្បុរសនេះ ត្រូវបានគេកេងចំណេញដោយអ្នកសាសនាដែលមិនមានភាពអៀនខ្មាស់ជាច្រើន រង់ចាំតែឱកាសដើម្បីអូសទាញតាមគ្រប់មធ្យោបាយ ។

ពុទ្ធសាសនិកប្រកបដោយបញ្ញា ត្រូវតែដឹងនូវកលល្បិចនេះ ។ គ្មានមនុស្សមានបញ្ញា និងប្រកបដោយឧត្តមគតិ ដែលយល់ច្បាស់នូវអ្វីដែលខ្លួនជឿជាក់តាមជំនឿស៊ប់របស់ខ្លួន បែរជាបោះបង់ចោលនូវជំនឿនោះ ដោយគ្រាន់តែដើម្បីបំពេញនូវតម្រូវការ ដែលមនុស្សធ្វើឡើងចំពោះសាសនាដទៃមួយទៀតឡើយ ។ ពុទ្ធសាសនិកមិនបានតម្រូវឱ្យដៃគូ

របស់ខ្លួនកាន់យកព្រះពុទ្ធសាសនានោះទេ ទាំងដែលខ្លួនក៏មិនបោះបង់ចោលនូវជំនឿផ្ទាល់ខ្លួនឯងផ្ទាល់នោះដែរ ។

## *សេចក្តីទុក្ខព្រួយក្រោយអាពាហ៍ពិពាហ៍*

កាលដែលយុវវ័យធ្លាក់ក្នុងសេចក្តីស្នេហា ពួកគេបានត្រៀមជាស្រេចក្នុងការធ្វើពលិកម្មជាច្រើន ដើម្បីឱ្យខ្លួនបានរៀបអាពាហ៍ពិពាហ៍សិន ប៉ុន្តែក្រោយពីនោះមកពីរទៅបីឆ្នាំ នៅពេលដែលភារកិច្ចជាក់ស្តែងក្នុងការកសាងជីវិតអាពាហ៍ពិពាហ៍ឱ្យជោគជ័យនោះ បានចាប់ផ្តើមហើយសេចក្តីខកបំណងក៏ចូលមកទន្ទឹមគ្នាដែរ ។ កាលដែគូដែលបានបោះបង់ជំនឿសាសនាដ៏ជ្រាលជ្រៅរបស់ខ្លួន ដើម្បី "សេចក្តីស្នេហា" ចាប់ផ្តើមស្តាយក្រោយក្នុងការដែលខ្លួនបានធ្វើដូច្នោះ ការយល់ខុសដែលមិនមានន័យក៏កើតឡើង ។ បញ្ហាទាំងអស់នេះបានផ្តល់បន្ថែមនូវភាពតានតឹងក្នុងអំឡុងពេលមួយ នៅពេលណាដែលមានភាពធុញទ្រាន់ក្នុងជីវិតអាពាហ៍-ពិពាហ៍ ហេតុនោះក៏នឹងនាំឱ្យមានជម្លោះកើតឡើង ។ ហើយជាធម្មតាមូលហេតុមួយដ៏ចំបងនៃជម្លោះនឹងចោទជាសំនួរឡើងថាតើកូន១ ត្រូវស្ថិតក្នុងសាសនាណាមួយ?

ម្ល៉ោះហើយ រឿងនេះមានសារៈសំខាន់ណាស់សម្រាប់បុគ្គលម្នាក់ៗក្នុងការដឹងថា ប្រសិនបើដំណើរការណ៍ផ្លាស់ប្តូរសាសនា មកពាក់ព័ន្ធហើយ វាត្រូវតែផ្អែកលើជំនឿពិតប្រាកដ មិនមែនគ្រាន់តែជាការសមរម្យ ឬការចាប់បង្ខំនោះទេ។ ពុទ្ធសាសនារក្សានូវសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងការជ្រើសរើស។ គោលការណ៍នេះ គប្បីត្រូវបានគោរពដោយមនុស្សគ្រប់គ្នាទើបជាការប្រសើរ។

## *វិធីរៀបមង្គលការ*

ពុំមានពិធីឬដំណើរការណ៍របស់ពុទ្ធសាសនាជាក់លាក់ទេ សម្រាប់ការប្រារព្ធអាពាហ៍ពិពាហ៍ តែពុទ្ធសាសនាទទួលស្គាល់នូវប្រពៃណី និងវប្បធម៌ ដែលអនុវត្តដោយប្រជាជនក្នុងប្រទេសផ្សេងៗ។ ដូច្នេះហើយ ពិធីធ្វើតាមបែបពុទ្ធសាសនាខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។

ការអនុវត្តជាទូទៅ សេវាកិច្ចសាសនាសម្រាប់ការប្រសិទ្ធិពរជ័យសិរីបវរ និងដើម្បីផ្តល់នូវឱវាទដល់គូស្វាមីភរិយា គឺធ្វើឡើងជាលក្ខណៈប្រពៃណីមិនថានៅក្នុងវត្តអារាម ឬក៏នៅផ្ទះទេ ដើម្បីផ្តល់នូវខ្លឹមសារដ៏មហាប្រសើរដល់ពិធីអាពាហ៍ពិពាហ៍។ នាបច្ចុប្បន្ននេះ នៅក្នុងប្រទេសជាច្រើន ក្រៅពីការប្រសិទ្ធិពរជ័យសិរីបវរ អង្គការសាសនាក៏បានផ្តល់នូវ

អំណាចដ៏ឱឡារិក និងការចុះឈ្មោះអាពាហ៍ពិពាហ៍ មួយអន្លើដោយការចេញនូវលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ស្របច្បាប់ផងដែរ ។

ដោយច្រើន ចំណុចដែលសំខាន់បំផុត គឺថាគូស្វាមីភរិយាគួរតែមានភាពស្មោះត្រង់ ឥតវៀចវេរ ក្នុងបំណងដើម្បីនឹងសហការគ្នា និងយោគយល់គ្នា មិនត្រឹមតែក្នុងពេលមានសេចក្ដីសុខនោះទេ ប៉ុន្តែថែមទាំងនៅពេលណាដែលពួកគេប្រឈមមុខនឹងបញ្ហា ភាពលំបាកលំបិនទាំងឡាយផងដែរ ។

# ៦.សន្តិសុខ  គារវកិច្ច  និងការទទួលខុសត្រូវ

## *ការដឹងនូវភាពអសន្តិសុខ*

នៅក្នុងអតីតកាល  គ្មានករណីនេះដូចជាការចុះឈ្មោះក្នុងសំបុត្រអាពាហ៍ពិពាហ៍ឡើយ ។  បុរសស្ត្រីសម្រេចចិត្តទៅវិញទៅមកក្នុងការយកគ្នាជាប្តីប្រពន្ធ  ហើយក្រោយមកពួកគេរស់នៅជាមួយគ្នាទៅ ។  អាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានអនុវត្តក្នុងវត្តមាននៃសហគមន៍  ហើយការលែងលះគ្នាពុំសូវមានឡើយ ។  រឿងដែលសំខាន់បំផុតគឺថាពួកគេបង្កើតសេចក្តីស្នេហាពិត  ហើយគោរពនូវការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមកជានិច្ច

ការចុះអត្តាស៊ីវិល  មានសារៈសំខាន់ណាស់ក្នុងពេលបច្ចុប្បន្ននេះ  ដើម្បីធានានូវសន្តិសុខ  និងការការពារនូវទ្រព្យសម្បត្តិ  ព្រមទាំងកូនៗផង ។  ដោយសារតែការដឹងនូវអសន្តិសុខ  គូស្វាមីភរិយាត្រូវបង្កើតនូវអាពាហ៍ពិពាហ៍ស្របច្បាប់មួយ ដើម្បីធានាឱ្យពួកគេមានចំណងយ៉ាងស្របច្បាប  មិនអាចដើម្បីនឹងធ្វើព្រងើយកន្តើយចំពោះកាតព្វកិច្ច  ហើយមិនធ្វើទុក្ខបុកម្នេញចំពោះគ្នានឹងគ្នាឡើយ ។  ក្នុងពេលបច្ចុប្បន្ននេះគូស្វាមីភរិយា

មួយចំនួនមានដាក់កិច្ចសន្យាស្របច្បាប់ថែមទៀត ទៅលើអ្វីដែលនឹងកើតឡើងចំពោះទ្រព្យសម្បត្តិ ប្រសិនបើពួកគេលែងលះគ្នា។

## ស្វាមី និងភរិយា

យោងតាមការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ទាក់ទងរឿងអាពាហ៍ពិពាហ៍នេះ ***ស្វាមីអាចរំពឹងនូវគុណសម្បត្តិពីភរិយារបស់ខ្លួន ដូចមានចែងខាងក្រោយនេះ :***

-សេចក្តីស្រឡាញ់
-ការយកចិត្តទុកដាក់
-កាតព្វកិច្ចគ្រួសារ
-ភាពស្មោះត្រង់
- ការថែរក្សាកូន
- ការសន្សំសំចៃ
- ការផ្គត់ផ្គង់អាហារ
- ធ្វើឱ្យគាត់ស្ងប់អារម្មណ៍នៅពេលដែលគាត់ក្រោធខឹង
- ផ្អែមល្ហែមគ្រប់យ៉ាង

***ក្នុងការតបស្នងនោះ សេចក្តីរំពឹងរបស់ភរិយាពីស្វាមីគឺ :***

- ភាពទន់ភ្លន់

- សុភាពរាបសារ
- ភាពចេះរួសរាយ
- សន្តិសុខ
- យុត្តិធម៌
- ភក្តីភាព
- ភាពស្មោះត្រង់
- មិត្តភាពល្អ
- មានសីលធម៌

ក្រៅពីផ្នែកមនោសញ្ចេតនា និងកាមារម្មណ៍ គូស្វាមីភរិយានឹងត្រូវយកចិត្តទុកដាក់ចំពោះស្ថានភាពជីវិតពីមួយប្រចាំថ្ងៃ ថវិកា គ្រួសារ និងកាតព្វកិច្ចសង្គមផ្សេងៗ។ ដូច្នេះការពិភាក្សាគ្នាទៅវិញទៅមករវាងស្វាមីនិងភរិយាអំពីបញ្ហាគ្រួសារ អាចនឹងជួយបង្កើតបរិយាកាសគួរទុកចិត្ត និងយោគយល់គ្នាក្នុងការដោះស្រាយនូវបញ្ហាអ្វីក៏ដោយដែលកើតឡើង។

# ឱវាទរបស់ព្រះសម្មាសម្ពុទ្ធចំពោះគូស្វាមីភរិយា

## ១- ភរិយា

ក្នុងការទូន្មានស្ត្រីអំពីតួនាទីរបស់ខ្លួន ពីរឿងជីវិតអាពាហ៍ពិពាហ៍នោះ ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរថាសេចក្តីស្ងប់ ភាពសុខដុមរមនានៅផ្ទះពឹងផ្អែកយ៉ាងសម្បើមទៅលើស្ត្រី សមដូចសុភាសិតខ្មែរពោលថា "សម្លឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយា"។ ឱវាទរបស់ព្រះអង្គគឺជាភាពប្រាកដនិយមនិងការអនុវត្តជាក់ស្តែង នៅពេលដែលព្រះអង្គពន្យល់លក្ខណៈល្អៗ មួយចំនួននៃជីវិតពីមួយថ្ងៃទៅមួយថ្ងៃ ដែលស្ត្រីគួរនិងមិនគួរធ្វើនោះ។ ព្រះពុទ្ធអង្គផ្តល់ឱវាទនៅក្នុងឱកាសផ្សេងៗគ្នាថា ភរិយាគួរតែ :

-មិនមានចិត្តអាក្រក់ប្រឆាំងនឹងប្តីខ្លួន

-មិនឃោរឃៅ ទ្រគោះបោះបោក ឬប្រើអំណាច

-មិនចាយវាយប្រាក់កាសខ្ជះខ្ជាយ ប៉ុន្តែគួររស់នៅប្រកបដោយមាគ៌ាសេដ្ឋកិច្ច

-ថែរក្សានិងសន្សំសំចៃប្រាក់ចំណូលនិងទ្រព្យសម្បត្តិដែលស្វាមីរកបានមក

-តែងតែយកចិត្តទុកដាក់ និងភាពបរិសុទ្ធចិត្ត កាយ

-ប្រកបដោយភាពស្មោះត្រង់ មិនមានចិត្តផិតក្បត់

-មានសំដីទន់ភ្លន់ និងមានកាយប្រកបដោយភាពសុភាពរាបសារ

-សប្បុរស ម៉ឺងម៉ាត់ហ្មត់ចត់ និងឧស្សាហ៍ព្យាយាមក្នុងការងារ

-ប្រកបដោយចិត្តករុណាចំពោះស្វាមីខ្លួន មានឥរិយាបថស្មើចំពោះសេចក្តីស្រឡាញ់ និងការបារម្ភរបស់មាតា ក្នុងការការពារនូវកូនប្រុសតែមួយ

-សុភាពរម្យទម និងប្រកបដោយសេចក្តីគោរព

-ត្រជាក់ ស្ងប់ យោគយល់គ្នា បម្រើ មិនត្រឹមតែជាភរិយាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមិត្តភក្តិ និងអ្នកផ្តល់ប្រឹក្សានៅពេលណាមានតម្រូវការកើតឡើង។

នៅក្នុងសម័យពុទ្ធកាល មេសាសនាដទៃទៀត ក៏បាននិយាយផងដែរអំពីតួនាទី និងកាតព្វកិច្ចរបស់ភរិយាចំពោះស្វាមី ដោយសង្កត់ធ្ងន់ជាពិសេសទៅលើតួនាទីរបស់ភរិយា ក្នុងការបង្កើតកូនសម្រាប់ស្វាមីផ្តល់នូវការយកអាសាប្រកបដោយភាពស្មោះត្រង់ និងផ្តល់នូវសេចក្តីសុខនៃភាពជាស្វាមីភរិយាតែប៉ុណ្ណោះ។

សហគមន៍ខ្លះ ផ្តោតយ៉ាងជាក់លាក់អំពីការមានកូនប្រុសក្នុងគ្រួសារ ។ ពួកគេជឿថា កូនប្រុសមានភាពចាំបាច់ណាស់ ក្នុងការធ្វើនូវពិធីបុណ្យសពរបស់ពួកគេ ទើបជីវិតបរលោករបស់ពួកគេ នឹងបានល្អប្រ-

សើរឡើង។ ការបរាជ័យក្នុងការបានកូនប្រុសអំពីភរិយាទីមួយ បានផ្ដល់សេរីភាពឱ្យបុរសមានភរិយាមួយទៀត ដើម្បីបានកូនប្រុស។ ពុទ្ធសាសនាមិនបានគាំទ្រចំពោះជំនឿនេះឡើយ។ បើយោងទៅតាមព្រះសម្ពុទ្ធឱវាទដែលទ្រង់បានបង្រៀនអំពីច្បាប់កម្មនោះ បុគ្គលត្រូវទទួលខុសត្រូវចំពោះកម្មនិងផលនៃកម្មរបស់ខ្លួនផ្ទាល់។ មិនថាកូនប្រុស ឬកូនស្រីកើតឡើងកំណត់ដោយឪពុកឬម្ដាយឡើយ ប៉ុន្តែដោយកម្មរបស់កូននោះផ្ទាល់។ ហើយសុខុមាលភាពរបស់ឪពុក ឬជីតាមិនបាន ពឹងផ្អែកទៅលើកូនប្រុសឬចៅប្រុសនោះទេ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនផ្ទាល់។ ដូច្នេះហើយ យើងឃើញថាខុសទាំងស្រុងសម្រាប់បុរសក្នុងការស្ដីបន្ទោសភរិយា ឬសម្រាប់បុរសក្នុងការមានអារម្មណ៍ថាមិនមានសមត្ថ-ភាព កាលបើមិនបានកូនប្រុសនោះ។ ពុទ្ធឱវាទនេះជួយតម្រង់នូវការយល់ខុសរបស់មនុស្សជាច្រើន និងកាត់បន្ថយបាននូវសភាពនៃសេចក្ដីទុក្ខព្រួយបារម្ភរបស់ស្ត្រីទាំងឡាយដែលមិនអាចនឹងបង្កើតកូនប្រុស ដើម្បីធ្វើ "ពិធីរបស់ដូនតានោះ"។

បើទោះបីជាតួនាទីរបស់ភរិយាចំពោះស្វាមី ត្រូវបានបញ្ញត្តិក្នុងក្រមវិន័យរបស់ខុងជឺក៏ដោយ តែមិនបានបញ្ជាក់នូវតួនាទី និងកាតព្វកិច្ចរបស់ស្វាមីចំពោះភរិយាទេ។ ប៉ុន្តែនៅក្នុង ***សិង្គាលោវាទសូត្រ*** ព្រះសម្មា-

សម្តុទ្ធទ្រង់បានសម្តែងយ៉ាងច្បាស់លាស់ អំពីតួនាទីរបស់ស្វាមីចំពោះភរិយានិង និងតួនាទីរបស់ភរិយាចំពោះស្វាមី ។

## ២- ប្តី

ក្នុងការឆ្លើយតបទៅនឹងគ្រហស្ថ ចំពោះរបៀបដែលស្វាមីគប្បីជួយដល់ភរិយារបស់ខ្លួន ព្រះពុទ្ធអង្គបានបញ្ជាក់ថាស្វាមីគួរគប្បីផ្តល់កិត្តិយស និងគោរពភរិយារបស់ខ្លួន ដោយមានភាពស្មោះត្រង់ចំពោះនាង ផ្តល់អំណាចក្នុងការគ្រប់គ្រង់កិច្ចការផ្ទះដល់នាង និងដោយការផ្តល់នូវគ្រឿងសំអិតសំអាងផងដែរ ។ ពុទ្ធឱវាទនេះ ព្រះអង្គទ្រង់បានសម្តែងតាំងតែពីជាង ២៥ សតវត្សរ៍មុនមកម្ល៉េះ ប៉ុន្តែឱវាទនេះនៅតែល្អនិងមានប្រយោជន៏រហូតដល់សព្វថ្ងៃនេះ

ដោយការដឹងនូវទឹកចិត្តរបស់បុរស ដែលមានទំនោរចាត់ទុកខ្លួនថាឧត្តមខ្ពង់ខ្ពស់ ព្រះពុទ្ធអង្គបានធ្វើនូវការផ្លាស់ប្តូរ ដែលគួរកត់ចំណាំនិងលើកតំកើងនូវឋានៈរបស់ស្ត្រី ដោយការផ្តល់ឱវាទដ៏សាមញ្ញថា *ស្វាមីគប្បីផ្តល់នូវកិត្តិយស និងគោរពចំពោះភរិយារបស់ខ្លួន* ។ ស្វាមីគប្បីមានភាពស្មោះត្រង់ចំពោះភរិយាខ្លួន ដែលមានន័យថាស្វាមីគប្បីបំពេញ និងរក្សានូវកាតព្វកិច្ចអាពាហ៍ពិពាហ៍ចំពោះភរិយារបស់ខ្លួន ដូច្នេះការទ្រទ្រង់នូវភាព

ជឿជាក់ក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ ក្នុងអត្ថន័យនៃពាក្យពេចន៍គ្រប់ម៉ាត់។ ក្នុងនាមជាមេគ្រួសារ ស្វាមីតែងតែនៅខាងក្រៅផ្ទះដោយខានមិនបានព្រោះហេតុនោះ ស្វាមីគប្បីប្រគល់ផ្ទុកផ្ដាក់នូវកិច្ចការផ្ទះឱ្យដល់ភរិយា ដែលយើងចាត់ទុកថាជាអ្នករក្សា និងអ្នកចែកនូវទ្រព្យសម្បត្តិ និងជាអ្នកគ្រប់គ្រងសេដ្ឋកិច្ចផ្ទះ។ ការផ្គត់ផ្គង់នូវគ្រឿងសំអិតសំអាងកាយដល់ភរិយាគឺជានិមិត្តរូបនៃសេចក្ដីស្រឡាញ់ ការព្រួយបារម្ភនិងការយកចិត្តទុកដាក់របស់ស្វាមីស្រោចមកលើភរិយា។ ការអនុវត្តនូវនិមិត្តរូបនេះត្រូវបានអនុវត្តតាំងពីពេលដ៏យូរលង់ណាស់មកហើយ នៅក្នុងសហគមន៍ពុទ្ធសាសនិកជន តែជាអកុសលវាស្ថិតនៅក្នុងគ្រោះថ្នាក់ស្ទើរតែនឹងស្លាប់បង់សូន្យឈឹង ដោយសារតែឥទ្ធិពលនៃអរិយធមិសម័យទំនើបនេះ។

## *អតីតកាល*

នៅក្នុងអតីតកាល ដោយសារតែរចនាសម្ព័ន្ធសង្គមស្ទើរតែគ្រប់សហគមន៍ មានភាពខុសគ្នាពីអ្វីដែលយើងឃើញនៅពេលបច្ចុប្បន្ននេះ ស្វាមីនិងភរិយាពឹងពាក់គ្នាទៅវិញទៅមក មានការយោគយល់គ្នានឹងគ្នាហើយ ទំនាក់ទំនងនោះមានស្ថិរភាព ពីព្រោះបុគ្គលម្នាក់ៗដឹងយ៉ាងជាក់លាក់នូវអ្វីដែលជាតួនាទីរបស់ខ្លួនក្នុងភាពជាដៃគូ។ "*សេចក្ដីស្នេហា*" ដែលស្វាមីខ្លះ និងភរិយាខ្លះព្យាយាមបង្ហាញអ្នកដទៃ ដោយការឱបរឹតថើបគ្នា

ក្នុងទីសាធារណៈ មិនមែនជាការបង្ហាញយ៉ាងចាំបាច់នូវសេចក្តីស្រឡាញ់ ឬការយោគយល់គ្នាពិតប្រាកដនោះទេ។ នៅក្នុងអតីតកាល បើទោះបីជាគូស្វាមីភរិយាមិនបានបង្ហាញនូវសេចក្តីស្រឡាញ់ ឬអារម្មណ៍ខាងក្នុងជាសាធារណៈក៏ដោយ ពួកគេមានការយោគយល់គ្នា និងការគោរពគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅមិនទាំងអាចបំបែកបានផង។ ប្រពៃណីបុរាណដែលមនុស្សមានក្នុងប្រទេសខ្លះថា ភរិយាត្រូវតែបូជាជីវិតរបស់ខ្លួនក្រោយពីមរណភាពរបស់ស្វាមីខ្លួន ហើយប្រពៃណីដែលរារាំងស្ត្រីមេម៉ាយមិនឱ្យការរៀបការសាជាថ្មីនោះ វាជាប្រពៃណីចម្លែកមួយចំពោះព្រះពុទ្ធសាសនា។ ពុទ្ធសាសនាមិនបានចាត់ទុកភរិយាថាឱនថយជាងស្វាមីនោះទេ។

## សង្គមទំនើប

ស្ត្រីខ្លះមានអារម្មណ៍ថា ក្នុងការផ្តោតចិត្តទៅលើការថែទាំគ្រួសារ គឺជាការធ្វើឱ្យអាប់យស និងអភិរក្សនិយមពេកណាស់។ ជាការពិតណាស់ដែលថាក្នុងអតីតកាល ស្ត្រីត្រូវបានគេចាត់ទុកយ៉ាងអាក្រក់ ប៉ុន្តែការណ៍នេះគឺវាបណ្តាលមកពីអវិជ្ជាខាងផ្នែកបុរស ច្រើនជាងភាពទន់ខ្សោយពីកំណើតរបស់ស្ត្រីក្នុងទស្សនៈនៃការពឹងពាក់ស្ត្រីក្នុងការអប់រំថែទាំកូន។

ស្ត្រីទាំងឡាយបានព្យាយាមតស៊ូអស់ពេលយ៉ាងយូរ ដើម្បីបាននូវសមភាពជាមួយនឹងបុរសក្នុងវិស័យអប់រំ ជំនាញ នយោបាយ និងវិស័យដទៃទៀត។ ឥឡូវនេះពួកគេស្ថិតនៅស្មើនឹងបុរសរហូតដល់កម្រិតយ៉ាងសម្បើម។ ជាទូទៅបុរសមាននិន្នាការក្នុងការឈ្លានពានពីធម្មជាតិមក ហើយស្ត្រីមានទំនោរផ្នែកអារម្មណ៍ច្រើនជាង។ នៅក្នុងទិដ្ឋភាពក្នុងផ្ទះជាពិសេសនៅក្នុងបូព៌ាប្រទេស បុរសច្រើនមានឥទ្ធិពលជាមេគ្រួសារ ចំណែកស្ត្រីច្រើនតែស្ថិតនៅជាដៃគូអសកម្មប៉ុណ្ណោះ។ ចូរចងចាំថា "*អសកម្ម* " ក្នុងទីនេះមិនមែនមានន័យថា "*ទន់ខ្សោយ* "នោះទេ។ វាជាគុណសម្បត្តិជាវិជ្ជមាននៃ "*ភាពទន់ភ្លន់ និងសុភាពរាបសា* " ទេវិញទេ។ ប្រសិនបើបុរសនិងស្ត្រីរក្សានូវ លក្ខណសម្បត្តិនៃបុរសភេទ និងស្ត្រីភេទរបស់ខ្លួនដែលទទួលបានពីធម្មជាតិមក ហើយទទួលស្គាល់នូវថាមពលរៀងៗខ្លួននោះ ទើបឥរិយាបថនោះអាចជាវិភាគទានចំពោះការយោគយល់គ្នាមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅវិញទៅមករវាងភេទទាំងពីរនេះ។

Gandhi's remarks:

*"I believe in the proper education of woman. But do believe that woman will not make her contribution to the world by mimicking or running a race with man. She can run the race, but she will not rise to the great heights she is capable of by mimicking man. She has to be the complement of man".*

## កំណត់សម្គាល់របស់មហាត្មៈគន្ធី

*" ខ្ញុំជឿជាក់ក្នុងការអប់រំដ៏ត្រឹមត្រូវរបស់ស្ត្រី ប៉ុន្តែកាន់តែជឿជាក់ថាស្ត្រីនឹងមិនធ្វើការវិភាគទានរបស់នាងដល់ពិភពលោក ដោយការធ្វើត្រាប់ ឬក៏រត់ប្រណាំងជាមួយនឹងបុរសឡើយ ។ នាងអាចរត់ប្រណាំងបាន ប៉ុន្តែនាងនឹងមិនឡើងទៅកាន់ទីខ្ពស់ដ៏ក្រៃលែង ដូចដែលមានសមត្ថភាព ដោយការធ្វើត្រាប់តាមបុរសនោះទេ ។ នាងត្រូវតែជាភាគបន្ថែមរបស់បុរស "* ។

## *ការទទួលខុសត្រូវនៃមាតាបិតា*

មូលដ្ឋាននៃសង្គមមនុស្សទាំងអស់ គឺទំនាក់ទំនងដែលស្មុគស្មាញរវាងឪពុកម្តាយនិងកូន។ តួនាទីរបស់ម្តាយគឺការស្រឡាញ់ ការយកចិត្តទុកដាក់និងការពារកូនសូម្បីតែម្តាយនោះត្រូវលះបង់អ្វីៗក៏ដោយ។ នេះគឺជាការបូជាខ្លួនចំពោះសេចក្តីស្រឡាញ់ ដែលព្រះពុទ្ធអង្គទ្រង់បានត្រាស់បង្រៀនហើយ។ វាជាការជាក់ស្តែង ការយកចិត្តទុកដាក់ និងសប្បុរសហើយវាមិនមែនជាអាត្មានិយមនោះទេ។ ព្រះពុទ្ធអង្គបានសម្តែងដល់ពុទ្ធសាសនិកជនទាំងឡាយថាឪពុកម្តាយគប្បីថែរក្សាកូន ដូចជាផែនដីទ្រទ្រង់នូវសព្វសត្វ និងរុក្ខជាតិទាំងពួងយ៉ាងដូច្នោះដែរ។

ឪពុកម្តាយត្រូវទទួលខុសត្រូវចំពោះសុខុមាលភាព និងការចិញ្ចឹមបីបាច់អប់រំកូនរបស់ខ្លួន។ ប្រសិនបើពួកគេធំធាត់ឡើងជាប្រជាពលរដ្ឋដែលមានកម្លាំងពលំមានសុខភាពល្អ និងមានប្រយោជន៍ វាគឺជាលទ្ធផលនៃការព្យាយាមរបស់ឪពុកម្តាយ តែប្រសិនបើពួកគេធំធាត់ឡើងជាអ្នកប្រព្រឹត្តបទល្មើសជាដើម ឪពុកម្តាយត្រូវតែទទួលខុសត្រូវ។ ឪពុកម្តាយមិនត្រូវបន្ទោសអ្នកដទៃឬសង្គមទេ ប្រសិនបើកូនដើរខុសគន្លងនោះ វាគឺជាតួនាទីរបស់ឪពុកម្តាយក្នុងការដឹកនាំកូនៗ ឱ្យទៅតាមផ្លូវត្រូវ។

នៅក្នុងវ័យដែលងាយនឹងទទួលនូវឥទ្ធិពលពីបរិស្ថានជុំវិញ កូនៗត្រូវការនូវសេចក្តីស្រឡាញ់ ការថ្នាក់ថ្នម និងការយកចិត្តទុកដាក់របស់ឪពុកម្តាយ។ បើគ្មានការស្រឡាញ់ និងការដឹកនាំរបស់ឪពុកម្តាយទេ កូនអាចនឹងវិកលវិការ ហើយនឹងយល់ថាពិភពលោកនេះថាជាកន្លែងសុញ្ញគំនិតមិនគួររស់នៅបានឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ការស្រោចស្រពនូវសេចក្តីស្រឡាញ់ ការព្រួយបារម្ភ និងការយកចិត្តទុកដាក់របស់ឪពុកម្តាយមិនមែនមានន័យថាផ្គាប់ចិត្តចំពោះរាល់តម្រូវការរបស់កូនៗ ប្រកបដោយហេតុផលសមរម្យ ឬយ៉ាងដទៃនោះទេ។ ការផ្គាប់ចិត្តខ្លាំងពេកអាចនឹងជាការទំរើសកូនហួសហេតុ។ ក្នុងការឱ្យនូវសេចក្តីស្រឡាញ់ និងការព្រួយបារម្ភនោះ ម្តាយគប្បីតឹងរឹង និងម៉ឺងម៉ាត់ផងដែរក្នុងការធ្វើឱ្យកូនស្តាប់បង្គាប់នោះ។ ដោយភាពតឹងរឹង និងម៉ឺងម៉ាត់មិនមែនមានន័យថា

ទ្រគោះបោះបោកចំពោះកូននោះទេ។ ចូរអ្នកបង្ហាញនូវសេចក្តីស្រឡាញ់របស់អ្នក ប៉ុន្តែត្រូវសម្រួលដោយវិន័យ ទើបកូននឹងយល់បាន។

ជាអកុសល បណ្តាឪពុកម្តាយនាពេលបច្ចុប្បន្ននេះ សេចក្តីស្រឡាញ់របស់ពួកគាត់កំពុងតែខ្វះខាតយ៉ាងគួរឱ្យសោកសៅ លាយច្រឡំបល់ជាមួយការរីកចម្រើនផ្នែកសម្ភារៈ ចលនាសេរីភាព និងសេចក្តីប្រាថ្នាចង់បានសមភាពបានបណ្តាលឱ្យម្តាយជាច្រើន ចូលរួមជាមួយស្វាមីរបស់ខ្លួនចំណាយពេលធ្វើការរបស់ខ្លួននៅក្នុងការិយាល័យ និងហាងច្រើនជាងការស្ថិតនៅក្នុងផ្ទះមើលថែរក្សាកូនរបស់ខ្លួនទៅវិញ។ ទុកការថែរក្សានេះឱ្យទៅញាតិមិត្ត ឬជួលអ្នកបម្រើ កូនៗសុញគំនិតមិនយល់ពីសេចក្តីស្រឡាញ់និងការយកចិត្តទុកដាក់របស់ម្តាយឡើយ។ ម្តាយមានអារម្មណ៍អៀនចំពោះកង្វះខាតនូវការយកចិត្តទុកដាក់ចំពោះកូនៗ បានខិតខំខ្លួនព្យាយាមលួងលោមកូនៗដោយការឱ្យនូវអ្វីៗជាសម្ភារៈដែលជាតម្រូវការរបស់កូន។ សកម្មភាពបែបនេះធ្វើឱ្យខូចក្មេង។ ការផ្តល់ឱ្យកូនៗនូវប្រភេទនៃតុក្កតាទំនើបៗ ដូចជារថក្រោះ កាំភ្លើងយន្ត កាំភ្លើងដៃ ដាវ និងប្រភេទសម្ភារៈជាការធ្វើឱ្យស្ងប់ចិត្តគឺមិនល្អប្រសើរសម្រាប់ផ្នែកចិត្តសាស្ត្រឡើយ។

ការផ្តុកផ្តាក់កូនដោយតុក្កតាប្រភេទនេះ មិនមែនអាចជំនួសបានឡើយសម្រាប់សេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមដ៏ផ្អែមល្ហែមរបស់មាតា

នោះ។ កង្វះខាតនូវសេចក្តីស្រឡាញ់ និងការដឹកនាំរបស់ឪពុកម្តាយនោះ វានឹងមិនមែនជាការភ្ញាក់ផ្អើលទេ ប្រសិនបើកូននោះធំឡើងជាលំដាប់ ក្លាយជាអ្នកប្រព្រឹត្តបទល្មើសឆ្គាំឆ្គង បន្ទាប់មកតើនរណាគួរត្រូវបន្ទោស សម្រាប់ការអប់រំកូនចចេសរឹងរូសនេះ? ជាការពិត គឺឪពុកម្តាយហ្នឹងឯង។ ម្តាយដែលមានការងាធ្វើនៅខាងក្រៅ ជាពិសេសបន្ទាប់ពីធ្វើការងាររហត់ពេញមួយថ្ងៃនៅក្នុងការិយាល័យមកហើយ ហើយមានមុខងារផ្ទះបន្តតាមក្រោយទៀតនោះអាចនឹងរកពេលបានដោយលំបាក សម្រាប់កូន១ ដែលកំពុងចង់បាននូវការថែរក្សា និងការយកចិត្តទុកដាក់របស់ម្តាយនោះ។ ឪពុកម្តាយដែលមិនមានពេលសម្រាប់កូន១របស់ខ្លួនពុំគប្បីត្អូញត្អែរឡើយ នៅពេលកូនដដែលទាំងនោះ មិនមានពេលសម្រាប់ពួកខ្លួននៅពេលដែលខ្លួនចាស់ទៅ។ ឪពុកម្តាយដែលពោលថាពួកគាត់បានចំណាយលុយយ៉ាងច្រើនទៅលើកូន១របស់ខ្លួន ប៉ុន្តែជាប់រវល់កិច្ចការយ៉ាងមមាញឹក មិនគួរត្អូញត្អែរទេ នៅពេលដែលកូនរបស់ខ្លួនជាប់រវល់វិញ ទុកពួកគាត់ឱ្យនៅក្នុងផ្ទះសម្រាប់មនុស្សចាស់នោះ។

ស្ត្រីធ្វើការបច្ចុប្បន្នភាគច្រើន ដើម្បីធ្វើឱ្យគ្រួសារអាចសប្បាយរីករាយចំពោះប្រយោជន៍ផ្នែកសម្ភារៈច្រើនថែមទៀត។ ពួកគាត់គួរតែពិចារណានូវឱវាទរបស់មហាត្មៈគន្ធីឱ្យបានហ្មត់ចត់ សម្រាប់បុរសក្នុងការស្វែងរកសេរីភាពពីលោភៈ ច្រើនជាងសេរីភាពពីតម្រូវការ។ ជាការពិត

ណាស់ ការផ្តល់នូវសេដ្ឋកិច្ចបច្ចុប្បន្នត្រូវបានបង្កើតឡើង យើងមិនអាចបដិសេធថាម្តាយខ្លះត្រូវបង្ខំឱ្យធ្វើការឡើយ ។ ក្នុងករណីប្រភេទនេះ ឪពុកម្តាយត្រូវធ្វើការចំណាយពេលវេលារបស់ខ្លួនបន្ថែមទៀត ដើម្បីទូទាត់សងនូវអ្វីៗដែលកូនរបស់ខ្លួនខកខាន នៅពេលពួកគេទៅឆ្ងាយ ។ ប្រសិនបើ ឪពុកម្តាយទាំងពីរនាក់ចំណាយម៉ោងសម្រាកពីការងាររបស់ខ្លួន រួចនៅផ្ទះជាមួយកូនៗនោះ វានឹងមានការយោគយល់គ្នាកាន់តែប្រសើរឡើងរវាងឪពុកម្តាយនិងកូនៗ ។

នៅក្នុងព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់បានធ្វើជាតារាងនូវតួនាទីនិងកិច្ចចំបងយ៉ាងជាក់លាក់ ជាមគ្គុទ្ទេសក៍ដ៏មានសារៈសំខាន់សម្រាប់ឪពុកម្តាយអនុវត្ត ។ មគ្គុទ្ទេសក៍ចំបងមួយក្នុងចំណោមនោះ គឺការប្រតិបត្តិនិងការងារដោយក្រឹត្យក្រម ដើម្បីដឹកនាំកូនៗចេញឆ្ងាយចាកវត្ថុដែលអាក្រក់ ហើយតាមរយៈការបញ្ចុះបញ្ចូលយ៉ាងទន់ភ្លន់ ដើម្បីដឹកនាំពួកគេឱ្យធ្វើអំពើល្អគ្រប់យ៉ាងសម្រាប់គ្រួសារ សង្គម និងប្រទេសជាតិ ។ នៅក្នុងទំនាក់ទំនងនេះ ឪពុកម្តាយអាចនឹងត្រូវអនុវត្តនូវការយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយនឹងកូនៗរបស់ខ្លួន វាមិនមែនជាអ្វីដែលឪពុកម្តាយបង្រៀនទេ ប៉ុន្តែជាអ្វីដែលពួកគេពិតជាធ្វើ ដែលកូនស្រូបយកដោយមិនដឹងខ្លួន និងដោយសេចក្តីស្រឡាញ់ទៀតផង ។ ការចូលទៅកាន់ពិភពលោករបស់កូនៗគឺត្រូវសូនពុម្ពដោយដេញដើងតាមការប្រព្រឹត្តរបស់ឪពុកម្តាយ វាមានទំនងថា

ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។ ឪពុកម្ដាយដែលចំណាយពេលច្រើនជាមួយកូនៗរបស់ខ្លួន នឹងចម្លងនូវចរិតលក្ខណៈរបស់ខ្លួនទៅឱ្យកូនៗបានយ៉ាងល្អិតសុខុម។

## តួនាទីរបស់ឪពុកម្ដាយ

វាគឺជាតួនាទីរបស់ឪពុកម្ដាយក្នុងការមើលថែចំពោះសុខុមាលភាពនៃបុត្រធីតារបស់ខ្លួន។ ជាការពិត ឪពុកម្ដាយប្រកបដោយសេចក្ដីស្រឡាញ់ និងពេញដោយតួនាទីរែកពុននូវការទទួលខុសត្រូវយ៉ាងមានសេចក្ដីរីករាយ។ ដើម្បីដឹកនាំកូនៗដើរនៅលើផ្លូវត្រូវ ជាដំបូងឪពុកម្ដាយគប្បីធ្វើជាគំរូ ហើយដឹកនាំនូវជីវិតប្រកបដោយឧត្ដមគតិខ្ពស់។ ក្នុងការរំពឹងចង់ឱ្យកូនប្រកបដោយគុណតម្លៃនោះ វាមិនអាចប្រព្រឹត្តទៅរួចទេកាលបើឪពុកម្ដាយជាអ្នកមិនមាននូវគុណសម្បត្តិគ្រប់គ្រាន់នោះ។ ក្រៅពីសម្ពាយកម្មដែលកូនទទួលស្នងពីបុព្វជាតិនោះ ពួកគេនឹងទទួលនូវភាពខ្វះខាត និងសប្បុរសធម៌របស់ឪពុកម្ដាយដោយចៀសវាងមិនរួចផងដែរ។ ឪពុកម្ដាយដែលមានការទទួលខុសត្រូវខ្ពស់ គួរគប្បីកាន់យកនូវរាល់ការប្រុងប្រយ័ត្ន ដើម្បីកុំឱ្យចម្លងនូវនិស្ស័យដែលមិនគួរជាទីពេញចិត្តទៅឱ្យកូនក្នុងផ្ទៃរបស់ខ្លួន។ យោងតាម ***សិង្គាលោវាទសូត្រ*** មានកាតព្វកិច្ចប្រាំយ៉ាងដែលគប្បីបំពេញដោយឪពុកម្ដាយគឺ ៖

## ១) កាតព្វកិច្ចទីមួយ គឺហាមឃាត់កូនៗមិនឱ្យធ្វើអំពើអាក្រក់

ផ្ទះគឺជាសាលាដំបូង ហើយឪពុកម្តាយគឺជាបុព្វាចារ្យ។ ជាធម្មតា កូនៗចាប់យកមេរៀនបឋម ក្នុងសេចក្តីល្អឬអាក្រក់ពីឪពុកម្តាយរបស់វា។ ឪពុកម្តាយដែលមិនមានការប្រុងប្រយ័ត្ន បានបង្រៀនចំណេះដឹងដំបូង គឺ ការកុហក ការបោកប្រាស ភាពមិនស្មោះត្រង់ និយាយមួលបង្កាច់បង្ខូច ការសងសឹក អហិរិកៈ គឺសេចក្តីមិនខ្មាស និងអនោត្តប្បៈ សេចក្តីមិនខ្លាចបាប និងសកម្មភាពជាអកុសលផ្សេងៗទៀតឱ្យដល់កូនៗក្នុងអំឡុងពេលពួកគេនៅជាកុមារភាព។ ឪពុកម្តាយគួរតែប្រើបង្ហាញនូវការប្រព្រឹត្តជាគំរូ ហើយមិនគួរចម្លងនូវគុណវិបត្តិចូលទៅក្នុងផ្នត់គំនិតរបស់កូនៗឡើយ។

## ២) កាតព្វកិច្ចទីពីរ គឺបញ្ចុះបញ្ចូលកូនៗឱ្យធ្វើអំពើល្អ

ឪពុកម្តាយគឺជាគ្រូនៅផ្ទះ គ្រូគឺជាឪពុកម្តាយនៅសាលារៀន។ ទាំងឪពុកម្តាយនិងគ្រូត្រូវទទួលខុសត្រូវចំពោះអនាគត និងសុខុមាលភាពរបស់កូនៗដែលនឹងក្លាយទៅជាអ្វីតាមដែលពួកគេសូនឡើង ហើយពួកគេនឹងក្លាយជាយុវវ័យ។ ពួកគេអង្គុយនៅនឹងជើងរបស់យុវវ័យក្នុងអំឡុងពេលនៃអាយុកាលចង់ចេះចង់ដឹងរបស់ខ្លួន ពួកគេស្រូបយកនូវអ្វីដែលពួកគាត់បង្រៀន ហើយពួកគេដើរតាមគន្លងជើងរបស់ពួកគាត់។ ពួកគេត្រូវទទួលឥទ្ធិពលដោយចិត្តគំនិត ពាក្យសំដី និងកាយវិការរបស់ឪពុកម្តាយ។

ពិព្រោះវាជាកាតព្វកិច្ចរបស់ឪពុកម្តាយបែបនេះ ដើម្បីបង្កើតនូវបរិយា-កាសគួរជាទីចូលចិត្តបំផុត ទាំងនៅផ្ទះ និងទាំងនៅក្នុងសាលារៀន។

ភាពងាយស្រួល ការស្តាប់បង្គាប់ ការសហការ ឯកភាព ភាពក្លាហាន ការបូជាខ្លួន ភាពស្មោះត្រង់ ការត្រង់ឆ្ពោះទៅមុខ សេវាកិច្ច ការពឹងពាក់ខ្លួន ការមានសន្តានចិត្ត ការសន្សំសំចៃ ការសន្តោស ឥរិយា-បថល្អ ឆន្ទៈសាសនា និងគុណធម៌ល្អៗដទៃទៀត គប្បីត្រូវបណ្តុះឱ្យមាន នៅក្នុងផ្នត់គំនិតយុវវ័យរបស់ពួកគេជាកំហិត។ គ្រាប់ពូជដែលគេដាំហើយ ដូច្នេះជាទីបំផុតនឹងធំលូតលាស់ឡើងទៅជាដើមឈើ ដែលពេញផ្ទុកទៅដោយផ្លែ។

### ៣) *កាតព្វកិច្ចទីបី គឺផ្តល់ឱកាសឱ្យកូនទទួលបានការអប់រំល្អ*

ការសិក្សាដ៏សមរម្យគឺជាកេរដំណែលដ៏ប្រសើរបំផុត ដែលឪពុកម្តាយអាចចែកឱ្យកូនរបស់ខ្លួន មិនមានទ្រព្យដ៏មានតម្លៃលើសពីនេះទៀតឡើយ វាគឺជាមង្គលដ៏ឧត្តម ដែលឪពុកម្តាយអាចប្រគល់ឱ្យកូនៗរបស់ខ្លួននោះ។ ការសិក្សាអប់រំគប្បីត្រូវចែកដល់ពួកគេ ដោយគួរឱ្យចូលចិត្តនោះគឺពីវ័យកុមារនៅក្នុងបរិយាកាសសាសនា។ ការណ៍នេះមានប្រសិទ្ធិភាពយ៉ាងទូលំទូលាយទៅលើជីវិតរបស់ពួកគេ។

### ៤) កាតព្វកិច្ចទីបួន គឺឃើញថាពួកគេបានរៀបការជាមួយនឹងបុគ្គលសមរម្យ

អាពាហ៍ពិពាហ៍គឺជាកិច្ចដ៏ឱឡារិកមួយ ដែលជាប់ទាក់ទងដល់ការរស់នៅពេញមួយជីវិត ។ ឯកភាពនេះគប្បីត្រូវតែមូលតែមួយដែលមិនអាចនឹងរំលាយបានដោយងាយៗ ដូច្នេះអាពាហ៍ពិពាហ៍ត្រូវតែបង្ហាញពីគ្រប់ជ្រុង និងគ្រប់ទិដ្ឋភាពដើម្បីបំពេញទឹកចិត្តរបស់គ្រប់ភាគីទាំងអស់មុនពេលរៀបការ ។

យោងតាមវប្បធម៌ពុទ្ធសាសនា កាតព្វកិច្ចត្រូវជំនួសដោយសិទ្ធិ ។ ចូរឱ្យភាគីទាំងសងខាងកុំមានមានៈរឹងរូសពេក ប៉ុន្តែត្រូវប្រើការប្រុងប្រយ័ត្នដែលប្រកបដោយប្រាជ្ញារបស់ខ្លួន ហើយចូលមកដល់ការរស់នៅប្រកបដោយមេត្រីភាពនឹងគ្នា ។ បើពុំនោះទេ វាអាចនឹងមានការជេរប្រទេចផ្តាសា និងការទង្គុកទង្គើដទៃទៀតដល់គ្នាទៅវិញទៅមក ហើយជាញឹកញាប់ជាងនេះ រោគឆ្លងនោះត្រូវចម្លងទៅដល់កូនចៅទៀតផង ។

### ៥) កាតព្វកិច្ចចុងក្រោយ គឺផ្តល់ឱ្យពួកគេនូវមត៌កនៅពេលដ៏សមគួរ

ឪពុកម្តាយស្រឡាញ់ និងថ្នាក់ថ្នមកូនៗរបស់ខ្លួន មិនត្រឹមតែនៅពេលដែលពួកគេស្ថិតនៅក្នុងការគ្រប់គ្រង អាណាព្យាបាលរបស់ខ្លួន

ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើការរៀបចំសម្រាប់ភាពស្រណុកសុខស្រួល នាពេលអនាគតរបស់ពួកគេទៀតផង ។ ពួកគាត់ស្វែងរកប្រមូលទ្រព្យសម្បត្តិនៅក្នុងកម្រិតនៃការលំបាកផ្ទាល់ខ្លួន ហើយផ្តល់នូវទ្រព្យទាំងនោះជាកេរដំណែលដល់កូនៗ ដោយពេញចិត្តពេញថ្លើមបំផុត ។

## *សាសនាប្រកបដោយករុណា*

ពុទ្ធសាសនាគឺជាសាសនាប្រកបដោយករុណា ហើយឪពុកម្តាយមិនគួរគប្បីភ្លេចណែនាំសាសនានេះដល់កូនៗឡើយ ដូចជាថាព្រះពុទ្ធអង្គទ្រង់បានសម្តែងនូវព្រះធម៌ ប្រកបដោយករុណាសម្រាប់ពិភពលោកទាំងមូល ។ ឪពុកម្តាយគប្បីប្រតិបត្តិតាម " *ព្រហ្មវិហារធម៌ទាំងបួន* " ដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធ ក្នុងការចិញ្ចឹមបីបាច់កូនរបស់ខ្លួនគឺ :

-មេត្តា : សេចក្តីស្រឡាញ់ ឬបំណងល្អ

-ករុណា : សេចក្តីអាណិតអាសូរ

-មុទិតា : សេចក្តីត្រេកអរ ភាពទន់ភ្លន់ទៅរកកូន

-ឧបេក្ខា : ភាពជាកណ្តាល ឬភាពជាអ្នកមានចិត្តស្មើ ។

ព្រហ្មវិហារធម៌ទាំងបួននេះ កាលបើត្រូវបានចម្រើនល្អហើយ នឹងជួយដល់ឪពុកម្ដាយឱ្យនៅបានសុខស្ងប់ ពេញមួយកំឡុងពេលលំបាកនៃការចិញ្ចឹមកូនៗដោយពិត។

នេះគឺជាមាគ៌ាដ៏ត្រឹមត្រូវ ឬមាគ៌ាគំរូប្រកបដោយឧត្ដមគតិនៃការប្រព្រឹត្តចំពោះសព្វសត្វទូទៅ។ ចិត្តដែលប្រកបដោយឥរិយាបថនៃព្រហ្ម-វិហារធម៌ទាំងបួននេះ ផ្ដល់នូវគម្រោងសម្រាប់ស្ថានភាពគ្រប់យ៉ាង ដែលកើតឡើងពីទំនាក់ទំនងសង្គម។ ព្រះធម៌នេះគឺជាសភាវៈកំចាត់បង់នូវភាពតានតឹងដ៏យ៉ាងខ្លាំងក្លា ជាគុណជាតិបង្កើតសន្តិភាពដ៏ប្រសើរក្រៃលែងនៅក្នុងជម្លោះសង្គម ជាឱសថដ៏ប្រសិទ្ធភាពសម្រាប់ព្យាបាលដំបៅដែលឈឺខ្លោកៗក្នុងការពុះពារសម្រាប់អត្ថិភាព ជាមាគ៌ាសម្រាប់ដោះស្រាយនូវរបាំងសង្គម ជាមធ្យោបាយសាងនូវសហគមន៍ប្រកបដោយសុខដុមរមនា ជាគ្រឿងដាស់តឿននូវសប្បុរស ដែលកំពុងដេកលង់លក់យូរ ជាសភាវៈប្រស់នូវសោមនស្សនិងក្ដីសង្ឃឹម ដែលត្រូវគេបោះបង់ចោលជាយូរមកហើយឱ្យរស់ឡើងវិញ និងជាធម៌ផ្សព្វផ្សាយនូវភាតរភាពនៃមនុស្សជាតិប្រឆាំងនឹងកម្លាំងផ្ដាច់ការនិយម។

ប្រហែលជាការប្រជែងដ៏សម្បើម ដែលគូស្វាមីភរិយាត្រូវតែប្រឈមមុខនោះ គឺការអប់រំដ៏ត្រឹមត្រូវដល់កូនៗ។ នេះជាទិដ្ឋភាពមួយ

ផ្សេងដោយឡែកទៀតដែលបែងចែកយើងឱ្យខុសពីសត្វតិរច្ឆាន។ ចំពោះសត្វតិរច្ឆានបានថែរក្សានូវកូនរបស់វាដោយការធ្វើពលីកម្មដ៏សម្បើម រីឯឪពុកម្តាយជាមនុស្សជាតិមានការទទួលខុសត្រូវខ្ពង់ខ្ពស់ជាង នោះគឺជាការអប់រំផ្លូវចិត្ត។ ព្រះសម្មាសម្ពុទ្ធបានត្រាស់ថាការប្រជែងដ៏ក្រៃលែងបំផុតដែលមនុស្សត្រូវប្រឈមនោះ គឺការអប់រំផ្លូវចិត្តពីព្រោះចាប់តាំងពីពេលកូនកើតមកនៅជាទារកឆ្លងកាត់វ័យក្មេងរហូតដល់ពេញវ័យ ឪពុកម្តាយទទួលខុសត្រូវជាចំបងចំពោះការវិវត្តផ្លូវចិត្តរបស់កូន។ មិនថាបុគ្គលនោះក្លាយជាពលរដ្ឋមានប្រយោជន៍ឬអត់ទេ ពឹងផ្អែកយ៉ាងសំខាន់ទៅលើការពង្រីកផ្លូវចិត្តរបស់ខ្លួនដែលត្រូវបានធ្វើឱ្យចម្រើនឡើង។ នៅក្នុងព្រះពុទ្ធសាសនា ឪពុកម្តាយដ៏ល្អអាចប្រតិបត្តិនូវគុណធម៌ទាំងឡាយបួន ដើម្បីទ្រទ្រង់ខ្លួន និងដើម្បីជំនះនូវភាពអស់សង្ឃឹមក្រៃលែង ដែលមានទំនាក់-ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងភាពជាមាតាបិតា។

កាលដែលកូននៅជាកូនក្មេង ទើបរៀនដើរតេសតាសនៅឡើយ វាមិនអាចនឹងបញ្ជាក់នូវតម្រូវការរបស់ខ្លួនបាន វាតែងតែពោបផ្កាប់មុខដើម្បីបញ្ចេញកំហឹងហើយស្រែកយំឡើងខ្លាំងៗ។ ឪពុកម្តាយដែលបានចម្រើននូវព្រហ្មវិហារធម៌ទី១គឺ **មេត្តា** អាចរក្សាសេចក្តីស្ងប់ក្នុងខ្លួនហើយបន្តស្រឡាញ់កូននាខណៈដែលមានការលំបាកខ្លាំង។ កូនដែលរីករាយ

ចំពោះផលរបស់មេត្តានេះ នឹងរៀនផ្សាយមេត្តាធម៌ដោយស្វ័យប្រវត្តិដោយខ្លួនឯង។

ខណៈដែលកូនក្លាយខ្លួនជាមនុស្សមានវ័យធំធាត់ហើយ ឪពុកម្តាយគប្បីចម្រើននូវករុណាចំពោះកូននោះ។ វ័យជំទង់គឺជាពេលដ៏លំបាកក្រៃលែងសម្រាប់កូនៗ។ កូនៗទាំងនោះបានចម្រើនដល់វ័យមួយដែលគេហៅថាវ័យជំទង់ ហេតុដូច្នេះហើយ ការមិនស្តាប់បង្គាប់ជាមួយនឹងទោសៈនិងភាពអស់សង្ឃឹមដ៏ក្រៃលែងរបស់ពួកគេ បានត្រង់ឆ្ពោះទៅរកឪពុកម្តាយរបស់ខ្លួន។ ដោយការចម្រើននូវករុណា ឪពុកម្តាយនឹងយល់ថាភាពរឹងរូសមិនស្តាប់បង្គាប់នេះ គឺជាផ្នែកមួយពីធម្មជាតិនៃការធំធាត់ហើយកូនៗទាំងឡាយមិនមានបំណង ដើម្បីធ្វើឱ្យឪពុកម្តាយរបស់ខ្លួនមានការឈឺចាប់ដោយចេតនានោះទេ។ កូនប្រកបដោយមេត្តានិងករុណានឹងក្លាយជាបុគ្គលល្អប្រសើរឡើងដោយខ្លួនឯង ក្រោយពីមិនមានទោសៈចំពោះខ្លួនឯងហើយគាត់នឹងផ្សាយមេត្តានិងករុណាទៅកាន់អ្នកដទៃថែមទៀតផង។

មុនពេលដែលគាត់ក្លាយជាយុវវ័យ កូននឹងប្រហែលជាជួបនឹងការជោគជ័យខ្លះៗក្នុងការប្រលង និងសកម្មភាពដទៃទៀតនៅខាងក្រៅផ្ទះ។ កាលនេះគឺជាពេលវេលាសម្រាប់ឪពុកម្តាយចម្រើននូវមុទិតា។ មានឪពុកម្តាយជាច្រើននៅក្នុងសង្គមទំនើបបានប្រើកូនៗ ឱ្យប្រកួតប្រជែង

ជាមួយនឹងមិត្តភក្តិរបស់ពួកគេ ពួកគាត់ចង់ឱ្យកូនៗរបស់ខ្លួនធ្វើបានល្អ សម្រាប់ហេតុផលអាត្មានិយម ទាំងអស់នេះ ព្រោះចង់ឱ្យអ្នកដទៃគិតល្អ អំពីខ្លួន។ ដោយការចម្រើននូវមុទិតា ឪពុកម្តាយនឹងត្រេកអរចំពោះ ជោគជ័យនិងសេចក្តីសុខរបស់កូនៗ ដោយគ្មានទង្វើ ឬហេតុលាក់កំបាំង ឡើយ...។ ឪពុកមានសេចក្តីរីករាយជាធម្មតា ពីព្រោះកូនរបស់គាត់មាន សេចក្តីរីករាយ។ កូនៗដែលត្រូវបានផ្សាយនូវផលនៃមុទិតានឹងក្លាយជា បុគ្គលដែលមិនមានការច្រណែនឈ្នានីសនឹងអ្នកដទៃដោយខ្លួនឯង ហើយ មិនមែនជាអ្នកដែលចូលចិត្តប្រកួតប្រជែងហួសហេតុនោះទេ។ បុគ្គលប្រ-ភេទនេះ នឹងមិនមានបន្ទប់នៅក្នុងបេះដូងរបស់ខ្លួនសម្រាប់ភាពអាត្មា-និយម ភាពលោភលន់ និងសេចក្តីក្រេវក្រោធឡើយ។

កាលដែលកូនឈានដល់ភាពជាយុវវ័យ ហើយមានការងារធ្វើ ព្រមទាំងមានគ្រួសារផងនោះ ឪពុកម្តាយគប្បីចម្រើននូវព្រហ្មវិហារធម៌ ចុងក្រោយគឺឧបេក្ខា។ នេះគឺជារឿងមួយដ៏លំបាកបំផុតសម្រាប់ឪពុក-ម្តាយនៅទ្វីបអាស៊ីក្នុងការអនុវត្តធម៌នេះ។ វាជាការពិបាកណាស់សម្រាប់ ឪពុកម្តាយក្នុងការអនុញ្ញាតកូនៗរបស់ខ្លួនឱ្យស្ថិតនៅឯករាជ្យ ក្នុងសិទ្ធិ ផ្ទាល់ខ្លួនរបស់ពួកគេនោះ។ កាលបើឪពុកម្តាយចម្រើននូវឧបេក្ខា ពួកគាត់ នឹងមិនចូលទៅជ្រៀតជ្រែកកិច្ចការរបស់កូនៗឡើយ ហើយមិនអាត្មា-និយមក្នុងការទាមទារពេលវេលា និងការយកចិត្តទុកដាក់ច្រើនជាងកូនៗ

អាចឱ្យបាននោះទេ។ យុវវ័យនៅក្នុងសង្គមសម័យទំនើបមានបញ្ហាយ៉ាងច្រើន។ ឪពុកម្តាយដែលមានការយល់ដឹងចំពោះគូស្វាមីភរិយាក្មេងៗមិនបានដាក់បន្ទុកធ្ងន់បន្ថែមទៀតដោយការ មិនបង្កើតនូវតម្រូវការដែលមិនចាំបាច់ទៅលើពួកគេឡើយ។ ជាសំខាន់បំផុតនោះ ឪពុកម្តាយចាស់គួរព្យាយាមកុំធ្វើឱ្យកូនៗ ដែលបានរៀបអាពាហ៍ពិពាហ៍ហើយមានអារម្មណ៍រង្កៀសដោយការធ្វើឱ្យពួកគេមានអារម្មណ៍ថាពួកគេបានប្រងើយកន្តើយចំពោះកាតព្វកិច្ចជាកូននោះឡើយ។ ប្រសិនបើឪពុកម្តាយបានចម្រើននូវឧបេក្ខាល្អហើយ ពួកគាត់នឹងស្ថិតនៅយ៉ាងស្ងប់ស្ងាត់នៅក្នុងវ័យជរារបស់ខ្លួន ព្រោះហេតុនោះហើយ ពួកគាត់បានទទួលនូវការគោរពពីក្មេងៗជំនាន់ក្រោយដោយពិត។

កាលឪពុកម្តាយផ្សាយនូវព្រហ្មវិហារធម៌ទាំងបួននេះ ដល់កូនៗរបស់ខ្លួនហើយ កូនៗទាំងនោះនឹងតបស្នងវិញគួរជាទីពេញចិត្ត ហើយបរិ-យាកាសមួយប្រកបដោយភាពរីករាយនឹងមាននៅក្នុងផ្ទះជាមិនខាន។ ផ្ទះដែលមានធម៌មេត្តា ករុណា មុទិតា និងឧបេក្ខានោះ គឺជាផ្ទះដែលពោរពេញដោយភាពសប្បាយរីករាយ។ កូនដែលធំឡើងក្រោមបរិយាកាសបែបនេះនឹងធំឡើងទៅជាអ្នកធ្វើការមានភាពយោគយល់ មានសេចក្តីករុណាប្រកបដោយឆន្ទៈខ្ពស់ និងជានិយោជកដែលចេះគិតពីអ្នកដទៃ។ នេះគឺជាមតិកដ៏ឧត្តមដែលឪពុកម្តាយអាចឱ្យកូនរបស់ខ្លួនបាន។

## ឪពុកម្តាយក្នុងសង្គមទំនើប

រឿងមួយបណ្តារឿងទាំងឡាយ ដែលពោរពេញដោយភាពក្រៀមក្រំបំផុតអំពីសង្គមទំនើបនោះ គឺកង្វះខាតនូវសេចក្តីស្រឡាញ់របស់ឪពុកម្តាយដែលកូនៗរងទុក្ខក្នុងប្រទេសដែលមានឧស្សាហកម្មខ្ពស់ ។កាលដែលគូស្វាមីភរិយារៀបអាពាហ៍ពិពាហ៍ ជាធម្មតាពួកគេមានគម្រោងក្នុងការមានចំនួនកូនតាមកំណត់ ហើយនៅពេលដែលកូនកើតមកភ្លាម ឪពុកម្តាយត្រូវជាប់ ជំពាក់ក្នុងការថែរក្សាកូននោះឱ្យអស់ពិសមត្ថភាពរបស់ខ្លួន។ ឪពុកម្តាយត្រូវមានការទទួលខុសត្រូវ ក្នុងការមើលឱ្យឃើញថាកូនមិនត្រឹមតែត្រូវផ្គាប់ចិត្តដោយសម្ភារៈប៉ុណ្ណោះទេ ផ្នែកស្មារតីបញ្ញា និងទិដ្ឋភាពផ្លូវចិត្តក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ។

ការផ្តល់នូវភាពស្រណុកសុខស្រួលផ្នែកសម្ភារៈ គឺជាខ្លឹមសារបន្ទាប់បន្សំទេ កាលបើប្រៀបទៅនឹងការផ្តល់នូវសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់របស់ឪពុកម្តាយនោះ។ យើងស្គាល់ឪពុកម្តាយជាច្រើនចេញពីគ្រួសារមិនសូវជាស្តុកស្តម្ភប៉ុន្មានទេ ដែលបានចិញ្ចឹមអប់រំកូនរបស់ខ្លួនបានយ៉ាងល្អ ហើយពោរពេញទៅដោយសេចក្តីស្រឡាញ់។ ម្យ៉ាងវិញទៀតគ្រួសារអ្នកមាន ជាច្រើនបានផ្តល់នូវភាពស្រណុកសុខស្រួលផ្នែកសម្ភារៈគ្រប់យ៉ាងសម្រាប់កូនរបស់ខ្លួន ប៉ុន្តែប្រាសចាកសេចក្តីស្រឡាញ់

របស់ឪពុកម្តាយទៅវិញ ។កូន១ ប្រភេទនេះនឹងគ្រាន់តែធំឡើងប៉ុណ្ណោះ គ្មាន ការចម្រើនសីលធម៌ និងផ្លូវចិត្តបន្តិចសោះឡើយ ។

ម្តាយគួរតែពិចារណាឱ្យបានហ្មត់ចត់ ថាតើនាងគួរតែបន្តធ្វើជាម្តាយដែលមានការងារធ្វើនៅក្រៅផ្ទះ ឬក៏ធ្វើជាមេផ្ទះដែលផ្តល់នូវសេចក្តីស្រឡាញ់គ្រប់យ៉ាង និងយកចិត្តទុកដាក់ចំពោះសេចក្តីសុខរបស់កូនដែលកំពុងតែធំធាត់នោះ ។ ជាការចំឡែកណាស់ ម្តាយសម័យថ្មីមួយចំនួនកំពុងត្រូវបានបង្ខិកឱ្យកាន់កាំភ្លើង និងសម្ភារៈដែលអាចបណ្តាលឱ្យស្លាប់បានផ្សេង១ទៀត នៅខណៈដែលពួកនាងគួរតែត្បុលចូលជិតកូន១របស់ខ្លួន ហើយអប់រំពួកគេឱ្យក្លាយជាប្រជាពលរដ្ឋល្អ និងជាអ្នកគោរពច្បាប់នោះ ។

និន្នាការសម័យទំនើប និងឥរិយាបថរបស់ម្តាយដែលធ្វើការក្រៅផ្ទះចំពោះកូនរបស់ខ្លួន ក៏ទោរទៅដើម្បីសឹករេចរឹលនូវតម្លៃនៃពេលវេលា សេចក្តីស្រឡាញ់ និងសេចក្តីអាណិតអាសូរដែលឪពុកម្តាយសង្ឃឹមថានឹងមានការតបស្នងពីកូនរបស់ខ្លួនទៅលើពួកគាត់វិញនោះ ។ ការជំនួសនូវការចិញ្ចឹមនឹងដោះ ដោយការចិញ្ចឹមនឹងដបក៏អាចជាកត្តាដទៃទៀតដែលជាចំណែកមួយ ឈានទៅដល់ការសឹករេចរឹលនៃក្តីស្រឡាញ់រវាងម្តាយនឹងកូនផងដែរ ។ កាលម្តាយចិញ្ចឹមនឹងដោះ ហើយបីត្រកងកូនតូចក្នុងដៃរបស់ខ្លួន សេចក្តីស្រឡាញ់យ៉ាងស្រទន់រវាងម្តាយនឹងកូនមានកម្លាំងខ្លាំងក្លា និង

មានឥទ្ធិពលដែលម្តាយមានទៅលើកូនៗ សម្រាប់សុខុមាលភាពរបស់វា មានកម្លាំងដ៏ជ្រាលជ្រៅក្រៃលែង។ ស្ថិតនៅក្រោមកាលៈទេសៈបែបនេះ សេចក្តីស្រឡាញ់ និងការគោរពរបស់កូន ចំណងគ្រួសារ និងការស្តាប់បង្គាប់ នឹងមានវត្តមានជាក់ជាមិនខាន។ លក្ខណៈពិសេសនៃប្រពៃណីទាំងនេះគឺសម្រាប់សេចក្តីល្អ និងសុខុមាលភាពរបស់កូនៗដោយពិត វាស្រេចហើយតែនឹងឪពុកម្តាយ ជាពិសេសគឺម្តាយដែលត្រូវផ្តល់ឱ្យកូន។ ម្តាយត្រូវទទួលខុសត្រូវចំពោះសេចក្តីល្អ ឬការចចេសរឹងរូសរបស់កូន ម្តាយអាចកាត់បន្ថយនូវការឆ្គាំឆ្គងនេះបាន។

## ការគ្រប់គ្រងរបស់ឪពុកម្តាយ

ឪពុកម្តាយជាច្រើនព្យាយាមទុកដាក់កូន ដែលរៀបអាពាហ៍-ពិពាហ៍ហើយឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ពួកគាត់មិនបានផ្តល់នូវសេរីភាពដល់កូនៗ ថែមទាំងចូលចិត្តជ្រៀតជ្រែកចំពោះជីវិតគូស្វាមីភរិយាវ័យក្មេងនោះទៀតផង។ កាលដែលឪពុកម្តាយព្យាយាមគ្រប់គ្រងកូនប្រុស ឬកូនស្រីដែលមានគូស្រករហើយ ហើយចង់ឱ្យពួកគេដើរតាមមាគ៌ាជីវិតរបស់ខ្លួនយ៉ាងតឹងរឹង ការណ៍នេះនឹងបង្កើតនូវការយល់ច្រឡំយ៉ាងច្រើនរវាងមនុស្សពីរជំនាន់នោះ ព្រមទាំងបង្កភាពមិនស្រណុកសុខស្រួលរវាងគូស្វាមីភរិយានោះផងដែរ។ ឪពុកម្តាយប្រហែលជាធ្វើ

ដូច្នេះក្នុងបំណងល្អព្រោះតែសេចក្ដីស្រឡាញ់ និងការជាប់ជំពាក់ចំពោះកូនៗទាំងនោះ ប៉ុន្ដែការធ្វើដូច្នេះពួកគាត់នឹងជួញឱ្យមានបញ្ហាកាន់តែច្រើនដល់ខ្លួនឯង និងកូនៗទៅវិញទេ។

ឪពុកម្ដាយត្រូវអនុញ្ញាតឱ្យកូនរបស់ខ្លួន ទទួលរ៉ាប់រងនូវការទទួលខុសត្រូវចំពោះជីវិត និងគ្រួសារពួកគេផ្ទាល់។ ឧទាហរណ៍ប្រសិនបើគ្រាប់ពូជធ្លាក់នៅក្រោមដើមឈើមួយ កូនរុក្ខជាតិអាចនឹងដុះឡើងនៅពេលណាមួយ ប៉ុន្ដែប្រសិនបើលោកអ្នកចង់ឱ្យរុក្ខជាតិទាំងនោះដុះឡើងដោយមានសុខភាព និងឯករាជ្យ លោកអ្នកត្រូវដកវាយកទៅដាំនៅទីវាលណាមួយផ្សេងទៀតដាច់ដោយឡែក ដើម្បីកុំឱ្យវាត្រូវគ្របដណ្ដប់ដោយម្លប់ដើមឈើចាស់នោះ។

ឪពុកម្ដាយមិនគួរព្រងើយកន្ដើយចំពោះប្រាជ្ញាបុរាណ ផ្អែកទៅលើឱវាទដែលបង្រៀនដោយមេសាសនា បណ្ឌិតជន និងចាស់ព្រឹទ្ធាចារ្យដែលបានចម្រើនវិជ្ជាផ្លូវលោកតាមរយៈការពិសោធន៍ និងកំហុសរបស់គាត់ផ្ទាល់នោះទេ។

## ការលែងលះ

ការលែងលះ គឺជាបញ្ហាចម្រូងចម្រាសមួយ ក្នុងចំណោមនៃអ្នកប្រតិបត្តិតាមសាសនាផ្សេងៗគ្នា។ មនុស្សខ្លះជឿថាអាពាហ៍ពិពាហ៍ត្រូវបានកត់ត្រាទុករួចហើយនៅក្នុងស្ថានសួគ៌ ដូច្នេះហើយវាមិនត្រឹមត្រូវនោះទេក្នុងការអនុញ្ញាតឱ្យមានការលែងលះគ្នានោះ។ ប៉ុន្តែប្រសិនបើស្វាមីភរិយាពិតជាមិនអាចរស់នៅជាមួយគ្នាបានមែន ជំនួសឱ្យការដឹកនាំជីវិតប្រកបដោយទុក្ខវេទនា និងក្រាញទ្រាំនៅប្រកបដោយការប្រច័ណ្ឌ ក្រេវក្រោធ និងទោសៈច្រើននោះ ពួកគេគួរតែមានសិទ្ធិសេរីភាពក្នុងការចែកផ្លូវគ្នា ហើយរស់នោះប្រកបដោយសេចក្ដីសុខស្ងប់។

## ការទទួលខុសត្រូវចំពោះកូនៗ

ទោះជាយ៉ាងណាក៏ដោយ ការចែកផ្លូវគ្នានៃគូស្វាមីភរិយាត្រូវតែធ្វើឡើងក្នុងបរិយាកាសនៃការយោគយល់គ្នា ដោយប្រកាន់យកដំណោះស្រាយប្រកបដោយហេតុផល និងដោយមិនបង្កើតសម្អប់កាន់តែខ្លាំងឡើងទៀត។ ប្រសិនបើគូស្វាមីភរិយាមានកូន ពួកគេគួរតែព្យាយាមធ្វើការលែងលះគ្នាដែលធ្វើឱ្យកូនៗស្លុតចិត្តតិច ហើយជួយសម្របសម្រួលពួកគេទៅនឹងស្ថានភាពថ្មី។ ហើយវាមានសារៈសំខាន់ណាស់ក្នុងការធានាថា

អនាគត និងសុខុមាលភាពរបស់ពួកគេនឹងត្រូវបានទទួលការយកចិត្តទុកដាក់។ វាគឺជាឥរិយាបថមួយដ៏អមនុស្សធម៌ណាស់ ប្រសិនបើស្វាមីភរិយានាំគ្នារត់ចោលពួកកូនៗ ហើយបណ្តោយឱ្យពួកគេរស់នៅប្រកបដោយទុក្ខវេទនានោះ។

## *ទស្សនៈព្រះពុទ្ធសាសនា*

ក្នុងពុទ្ធសាសនាមិនមានច្បាប់ដែលចែងថា ប្តីនិងប្រពន្ធមិនគួរចែកផ្លូវគ្នាទេ ប្រសិនបើពួកគេមិនអាចរស់នៅជាមួយគ្នាបានដោយសុខដុមរមនានោះ។ ប៉ុន្តែប្រសិនបើមនុស្សធ្វើតាមឱវាទ ដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធក្នុងការបំពេញនូវកាតព្វកិច្ចចំពោះគ្នានឹងគ្នានោះ ការកើតឡើងនូវរឿងជាអកុសលបែបនេះ ដូចជាការលែងលះ និងចែកផ្លូវគ្នានោះនឹងមិនដែលកើតមានឡើងឡើយ។

នៅក្នុងអតីតកាល ទីណាដែលតម្លៃសាសនាត្រូវបានគោរពយ៉ាងខ្ពង់ខ្ពស់នោះ នឹងមានសេចក្តីព្យាយាមដ៏សម្បើម ទៅលើចំណែកនៃគូអាពាហ៍ពិពាហ៍ ដូចជានៅក្នុងបូព៌ាប្រទេសនិងនៅក្នុងបស្ចិមប្រទេសដែរក្នុងការឈានដល់ការយោគយល់គ្នាប្រកបដោយមេត្រីភាព ដើម្បីអភិវឌ្ឍនូវទំនាក់ទំនងដ៏មានសេចក្តីសុខ ផ្អែកលើការគោរពស្រឡាញ់ និងមើលគ្នា

ទៅវិញទៅមក។ គូស្វាមីភរិយាបានចម្រើន ហើយធ្វើនូវអាពាហ៍ពិពាហ៍របស់ខ្លួនឱ្យមានទ្រង់ទ្រាយមួយប្រកបដោយសារៈសំខាន់ ដែលពួកគេស្រឡាញ់គ្នានៅក្នុងបេះដូងរៀងៗខ្លួន។ ករណីលែងលះគ្នា គឺកម្រនឹងមានណាស់ ហើយត្រូវបានចាត់ទុកថាជាភាពអាម៉ាស់មួយ ពីព្រោះពួកគេបានបង្ហាញនូវភាពអាត្មានិយមនៃគូភាគីម្ខាង ឬម្នាក់ដទៃទៀត។ វាជាការពិតដែលថារហូតមកដល់ពេលថ្មីៗនេះ ករណីលែងលះគ្នានៅតែក្រមានណាស់នៅក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា។ ការណ៍នេះភាគច្រើនគឺមកពីគូស្វាមីភរិយាចេះពិចារណានូវតួនាទី និងកាតព្វកិច្ចរបស់ខ្លួនចំពោះគ្នានឹងគ្នា ហើយជាមូលដ្ឋាននោះ ការលែងលះគ្នាមិនត្រូវបានយល់ព្រមដោយសហគមន៍ទាំងមូលផង។ នៅក្នុងករណីជាច្រើន កាលដែលគូស្វាមីភរិយាស្ថិតនៅក្នុងបញ្ហា ចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍តែងតែសម្របសម្រួលឱ្យជួបជុំគ្នា ហើយដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យស្ថានភាពនោះប្រសើរឡើងវិញ

ជាអកុសល នៅក្នុងសង្គមសម័យទំនើបបច្ចុប្បន្ននេះ ការលែងលះគ្នាបានក្លាយជាការអនុវត្តយ៉ាងសាមញ្ញទៅហើយ។ នៅក្នុងប្រទេសមួយចំនួនវាក៏ក្លាយទៅជារឿងអស្ចារ្យទៅទៀត ជាជាងការចាត់ទុករឿងលែងលះគ្នាថាជារឿងគួរឱ្យអាម៉ាស់ ឬជាការបរាជ័យដើម្បីរៀបចំនូវខ្សែជីវិតរបស់ពួកគេ ការបំបែកគូស្វាមីភរិយានោះ ក្មេងៗមានទំនងដូចមានមោទនៈចំពោះរឿងនោះណាស់។ មូលហេតុដ៏ចំបងនៃការបរាជ័យក្នុង

ជីវិតអាពាហ៍ពិពាហ៍ នៅក្នុងសង្គមទំនើប គឺជាការរំលោភបំពានដល់សេរីភាព ឯករាជ្យ និងបុគ្គលនិយម ទៅលើចំណែកនៃដៃគូខ្លាំងណាស់ ហើយវាត្រូវតែមានដែនកំណត់ចំពោះជីវិតឯករាជ្យរបស់ពួកគេ បើមិនដូច្នោះទេនោះ ទាំងស្វាមីទាំងភរិយានឹងវង្វេងផ្លូវយ៉ាងងាយ ។

## ៧.ពហុពន្ធភាព និងឯកពន្ធភាព[២]

ចំពោះសំនួរដែលថា តើពុទ្ធសាសនិកអាចមានប្រពន្ធលើសពីមួយបានដែរឬទេ? ចម្លើយផ្ទាល់នោះគឺមិនមាននៅក្នុងពុទ្ធឱវាទឡើយពីព្រោះដូចដែលបានពណ៌នាខាងដើមហើយ ព្រះពុទ្ធអង្គមិនបានបញ្ញត្តិនូវច្បាប់សាសនាណាមួយ ទាក់ទងនឹងជីវិតអាពាហ៍ពិពាហ៍ឡើយ បើទោះបីជាព្រះអង្គបានត្រាស់សម្តែងនូវឱវាទដ៏មានតម្លៃ អំពីរបៀបដឹកនាំជីវិតអាពាហ៍ពិពាហ៍ដ៏គួរឱ្យគោរពមួយក៏ដោយ ។

ប្រពៃណី វប្បធម៌ និងមាគ៌ាជីវិត ដូចដែលត្រូវបានទទួលស្គាល់ដោយមនុស្សភាគច្រើននៃប្រទេសជាក់លាក់នោះ ត្រូវតែពិចារណាផងដែរ នៅពេលយើងអនុវត្តនូវរឿងរ៉ាវដ៏ជាក់លាក់ ដែលជាប់ទាក់ទងនឹងជីវិតរបស់យើងនោះ។ សាសនាខ្លះអះអាងថា បុរសអាចមានប្រពន្ធត្រឹមតែមួយប៉ុណ្ណោះ ចំណែកសាសនាដទៃទៀតពោលថា បុរសអាចមានប្រពន្ធលើសពីមួយបាន។

បើទោះបីព្រះពុទ្ធអង្គមិនបានពណ៌នាពីអ្វីទាក់ទងនឹងចំនួនប្រពន្ធដែលបុរសអាចមានក៏ដោយ ព្រះអង្គបានសម្តែងយ៉ាងច្បាស់លាស់នៅក្នុង

២ , ពហុពន្ធភាព សំដៅដល់ការនិយមមានប្រពន្ធច្រើន រីឯឯកពន្ធភាពគឺការនិយមមានប្រពន្ធមួយ ។

ព្រះសូត្រ ថាបុរសដែលរៀបការហើយ ទៅរកស្ត្រីដទៃក្រៅពីប្រពន្ធខ្លួន នោះអាចនឹងក្លាយជាហេតុនៃសេចក្តីវិនាស ហើយគាត់អាចនឹងត្រូវប្រ-ឈមជាមួយនឹងបញ្ហា និងការរំខានដទៃទៀតជាច្រើន ជាពិសេសគឺរោគសង្គម មានរោគអេសដីជាដើម ។

មាតិកានៃព្រះពុទ្ធឱវាទ គឺគ្រាន់តែពន្យល់អំពីដើមហេតុ និងផលវិបាកប៉ុណ្ណោះ ។ មនុស្សអាចគិតដោយខ្លួនឯងបានថា ហេតុអ្វីបានជារឿងរ៉ាវមួយចំនួនល្អ ហើយរឿងរ៉ាវមួយចំនួនទៀតអាក្រក់ដូច្នេះ ។ ព្រះពុទ្ធអង្គមិនបានបញ្ញត្តិវិន័យ អំពីប្រពន្ធប៉ុន្មានដែលបុរសគប្បី ឬមិនគប្បីមាន ដែលមនុស្សត្រូវដើរតាមនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើច្បាប់ប្រទេសចែងល័ក្ខខ័ណ្ឌថា អាពាហ៍ពិពាហ៍ត្រូវតែមានប្រពន្ធតែមួយនោះ មនុស្សត្រូវតែគោរពតាមច្បាប់បែបនេះ ពីព្រោះព្រះពុទ្ធអង្គទ្រង់បានសម្តែងយ៉ាងច្បាស់ណាស់ អំពីបរិស័ទរបស់ព្រះអង្គ ក្នុងការគោរពច្បាប់ប្រទេសនោះ ប្រសិនបើច្បាប់ទាំងនោះជាប្រយោជន៍ដល់ជនទូទៅមែនពិតនោះ ។

# ៨-បច្ចេកវិទ្យាថ្មី

## ផែនការគ្រួសារ

សាសនាខ្លះ មិនយល់ស្របជាមួយនឹងផែនការគ្រួសារឡើយ។ ពុទ្ធសាសនា មិនបានជ្រៀតជ្រែកក្នុងជម្រើសផ្ទាល់ខ្លួននោះទេ។ បុរសមានសេរីភាពក្នុងការធ្វើតាមវិធីសាស្ត្រណាមួយ ដើម្បីការពារនូវការចាប់បដិសន្ធិ។ យោងតាមពុទ្ធសាសនា បច្ច័យផ្លូវកាយនិងផ្លូវចិត្តត្រូវមានវត្ត-មានសម្រាប់ឱ្យបដិសន្ធិកើតមានឡើង។ កាលបច្ច័យណាមួយក្នុងចំណោមបច្ច័យនោះមិនមានវត្តមានហើយ ដូចជាផែនការគ្រួសារកំពុងតែអនុវត្តមិនមានបដិសន្ធិកើតឡើងទេ ដូច្នេះជីវិតមិនកើតមានឡើងឡើយ។ ប៉ុន្តែក្រោយពេលមានបដិសន្ធិហើយ ការយកកូនចេញមិនអាចទទួលយកបានឡើយនៅក្នុងព្រះពុទ្ធសាសនា ពីព្រោះវាមានន័យថាធ្វើជីវិតសត្វឱ្យធ្លាក់ចុះកន្លង(សម្លាប់សត្វ) ដែលមានរូបនៅក្នុងស្បូនរួចហើយ។

## ទារកដែលកើតដោយសិប្បនិម្មិត

មនុស្សខ្លះមានចំណាប់អារម្មណ៍ ក្នុងការពោលមិនចំហដែលប្រ-កបដោយសីលធម៌ ឬឥរិយាបថបែបសាសនាទាក់ទងនឹងទារកដែលបង្កើតដោយសិប្បនិម្មិត។ ប្រសិនបើស្ត្រីពុំមានលទ្ធភាពឱ្យកំណើតកូនតាមវិធី

ធម្មតានោះ ហើយប្រសិនបើនាងអន្ទះសាចង់មានកូន ដោយការអនុវត្ត នូវវិធីសាស្រ្តពេទ្យទំនើបវិញ វាមិនមានមូលដ្ឋានទេនៅក្នុងពុទ្ធសាសនា ក្នុងការនិយាយថាអសីលធម៌ ឬខុសចាកច្បាប់សាសនានោះទេ។ សាសនា ត្រូវទទួលស្គាល់ចំពោះបញ្ហារបស់មនុស្ស និងត្រូវសម្របខ្លួនទៅនឹងការ រកឃើញថ្មីៗនៃវេជ្ជសាស្រ្តទំនើប ប្រសិនបើវាមិនធ្វើឱ្យអន្តរាយ ហើយជា ប្រយោជន៍ដល់មនុស្សជាតិទូទៅនោះ។ ដូចដែលបានពណ៌នាខាងដើមរួច ហើយ ដរាបណាហេតុបច្ច័យទាំងឡាយត្រឹមត្រូវហើយ បដិសន្ធិក៏អាច អនុញ្ញាតឱ្យមានឡើងដោយធម្មជាតិ ឬដោយសិប្បនិម្មិតក៏ដោយ។

## ៩. សីលធម៌

## ទំនាក់ទំនងផ្លូវភេទមុនអាពាហ៍ពិពាហ៍

ភេទសម្ព័ន្ធមុនអាពាហ៍ពិពាហ៍គឺជាបញ្ហាមួយ ដែលត្រូវបានគេធ្វើ ការពិភាក្សាយ៉ាងច្រើននៅក្នុងសង្គមទំនើប។ យុវវ័យជាច្រើនអាចនឹង ចូលចិត្តចង់ដឹងពីគំនិតទាក់ទងនឹងបញ្ហារំជើបរំជួលនេះ។ អ្នកសាសនាខ្លះ បាននិយាយថាវាអាចត្រូវពិចារណាថាជាការប្រព្រឹត្តខុសក្នុងកាម ចំណែក អ្នកដទៃទៀតនិយាយថាវាគឺជារឿងអសីលធម៌ និងមិនត្រឹមត្រូវសោះ ឡើយ។

នៅក្នុងអតីតកាល យុវជនយុវនារីមិនត្រូវបានអនុញ្ញាតដោយឪពុកម្តាយរបស់ខ្លួនឱ្យដើរហើរដោយសេរីឡើយ រហូតដល់ពេលដែលពួកគេរៀបការហើយ ។ អាពាហ៍ពិពាហ៍របស់ពួកគេក៏ត្រូវបានរៀបចំឡើងដោយឪពុកម្តាយដែរ ។ ជាការពិត ការណ៍នេះពិតជាបណ្តាលមកនូវសេចក្តីមិនសប្បាយចិត្ត ជាទុក្ខក្នុងករណីខ្លះនៅពេលដែលឪពុកម្តាយជ្រើសរើសដៃគូដែលផ្អែកទៅលើទឹកប្រាក់ ឋានៈក្នុងសង្គម កាតព្វកិច្ចគ្រួសារនិងបញ្ហាពាក់ព័ន្ធផ្សេងទៀត ប៉ុន្តែជាទូទៅភាគច្រើននៃឪពុកម្តាយពិតជាខំព្យាយាមយ៉ាងលំបាកក្នុងការជ្រើសរើសគូស្រករ ដែលអាចនឹងទទួលយកបានពីកូនខ្លួននោះ ។

សព្វថ្ងៃយុវវ័យទាំងឡាយ មានសេរីភាពក្នុងការចេញទៅក្រៅនិងស្វែងរកដៃគូផ្ទាល់ខ្លួន ពួកគេមានសេរីភាព និងឯករាជ្យយ៉ាងច្រើននៅក្នុងជីវិតរបស់ខ្លួន ។ នេះមិនមែនជារឿងអាក្រក់នោះទេ ប៉ុន្តែមនុស្សខ្លះក្នុងចំណោមយុវវ័យទាំងនោះនៅក្មេងពេក និងនៅមិនទាន់ទាំងពេញវ័យចាស់ក្លានៅឡើយ ក្នុងការមើលឃើញភាពខុសគ្នារវាងការទាក់ទាញផ្លូវភេទ និងភាពចុះសម្រុងគ្នាពិតប្រាកដនៅឡើយផង ព្រោះហេតុនោះទើបបញ្ហានៃភេទសម្ព័ន្ធមុនពេលរៀបការចេះតែកើតឡើង ។

ភាពធូររលុងខ្លាំងពេកក្នុងរឿងទាក់ទងនឹងភេទសម្ព័ន្ធនោះ ក៏បានបណ្តាលឱ្យកើតបញ្ហាសង្គមនៅក្នុងសង្គមទំនើបនេះ។ រឿងដ៏ក្រៀមក្រំនោះ គឺសង្គមខ្លះមិនបង្ហាញឥរិយាបថប្រកបដោយសេរីភាពចំពោះម្តាយទាំងឡាយដែលមិនទាន់រៀបការ កូនឥតខាន់ស្លា និងស្ត្រីប្តីលែងឡើយ តែសង្គមបែរជាប្រកាន់យកសេរីភាពនិយមយ៉ាងពេញលេញ ក្នុងការមានទំនាក់ទំនងផ្លូវភេទទៅវិញ។ ជាលទ្ធផល ក្មេងៗទាំងឡាយត្រូវទទួលទណ្ឌកម្មដោយសង្គមដដែលនោះ ដែលបានលើកទឹកចិត្តឱ្យមានការសេពគប់ដោយសេរីនៃការមានទំនាក់ទំនងផ្លូវភេទ។ ពួកគេបានក្លាយទៅជាមនុស្សសំណល់សង្គម ទទួលរងទុក្ខយ៉ាងខ្លាំង ភាពអាម៉ាស់ និងអាប់យសយ៉ាងក្រៃលែង។ មានស្ត្រីក្មេងៗជាច្រើនបានក្លាយជាជនរងគ្រោះ ដោយសារតែសេរីភាពរបស់ខ្លួនផ្ទាល់ ហើយបានធ្វើឱ្យបាត់បង់នូវអនាគតរបស់ខ្លួន ដោយការប្រព្រឹត្តកន្លងប្រពៃណីចាស់បុរាណ ដែលជាប្រពៃណីដ៏មានតម្លៃនៅក្នុងបូព៌ា និងបស្ចិមប្រទេសផងដែរ។

ការមានភេទសម្ព័ន្ធមុនពេលរៀបការ គឺជាការអភិវឌ្ឍទំនើបដែលបានកើតឡើង ជាលទ្ធផលនៃសេរីភាពសង្គមហួសប្រមាណដែលមានក្នុងចំណោមយុវវ័យនាពេលបច្ចុប្បន្ននេះ។ ចំណែកពុទ្ធសាសនាមិនបានប្រកាន់ទស្សនៈមាំទាំសម្រាប់គាំទ្រ ឬប្រឆាំងសកម្មភាពបែបនេះទេ វាគឺជាគំនិតដែលពុទ្ធសាសនិកទាំងអស់ ជាពិសេសមនុស្សទាំងពីរភេទដែល

ស្រឡាញ់គ្នា ហើយពិចារណាចំពោះអាពាហ៍ពិពាហ៍ គប្បីប្រកាន់យកតាមទស្សនៈប្រពៃណីបុរាណ ដែលពួកគេរក្សាភាពបរិសុទ្ធរហូតដល់ពេលរៀបការហើយ ។ ចិត្តរបស់មនុស្សមិនមានស្ថិរភាព ហើយតែងតែប្រែប្រួលជាមួយនឹងលទ្ធផលនោះហើយសកម្មភាពខុសច្បាប់ ឬអំពើដែលមិនចេះលាក់លៀមអាចិកំបាំងអាចនឹងបណ្តាលឱ្យបៀតបៀនចំពោះភាគីណាមួយ ប្រសិនបើអាពាហ៍ពិពាហ៍ស្របច្បាប់មិនកើតឡើង ដូចដែលបានរំពឹងទុកនោះ។ គេគួរតែចងចាំដែរថា ទ្រង់ទ្រាយនៃភាពត្រេកត្រអាលផ្លូវភេទណានីមួយមុនពេលមានអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលបានប្រព្រឹត្តទៅជាសាធារណៈនោះនឹងត្រូវទទួលការមើលងាយអំពីសំណាក់ចាស់ទុំ ដែលជាអាណាព្យាបាលរបស់ពួកយុវវ័យទាំងនោះ ។

## ***ការប្រព្រឹត្តខុសក្នុងកាម***

គ្រហស្ថត្រូវបានទូន្មាននៅក្នុងឱវាទរបស់ព្រះសម្ពុទ្ធ ឱ្យចៀសវាងការប្រព្រឹត្តខុសក្នុងកាម មានន័យថាប្រសិនបើបុគ្គលចង់ឆ្លងកាត់ការមានភេទមេត្រី គាត់ត្រូវធ្វើដូច្នោះដោយមិនបង្កើតនូវអំពើហិង្សា ឬដោយការប្រើប្រាស់កម្លាំងណាមួយមានគំរាមកំហែង ឬបង្កភាពភ័យខ្លាចឡើយ។ ដូច្នេះ បើជីវិតភេទសមរម្យដែលគោរពដៃគូដទៃ គឺជាការមិនប្រឆាំងនឹងសាសនានេះទេ។ សាសនាទទួលស្គាល់ការពិតថា វាគឺជាតម្រូវការមួយ

សម្រាប់មនុស្សម្នាក់ៗ ដែលនៅមិនទាន់បានលះបង់ជីវភាពលោកីយ៍ដាច់ស្រឡះនៅឡើយនោះ។

យោងតាមព្រះពុទ្ធសាសនា បុគ្គលដែលពាក់ព័ន្ធនៅក្នុងភេទសម្ព័ន្ធខាងក្រៅជាមួយនរណាម្នាក់ ដែលបានរៀបការរួចហើយ អ្នកដែលបានភ្ជាប់ពាក្យជាគូដណ្តឹងជនណាម្នាក់ផ្សេងទៀតហើយ និងជាមួយបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ ឬក៏អាណាព្យាបាលរបស់គេឈ្មោះថា មានទោសក្នុងការប្រព្រឹត្តខុសក្នុងកាម ពីព្រោះមានការកាត់នូវបទដ្ឋានសង្គមដែលភាគីទីបីត្រូវបានគេធ្វើឱ្យរងទុក្ខជាលទ្ធផលនៃភាពអាត្មានិយមរបស់បុគ្គលខ្លួន ឬបុគ្គលជាដៃគូដទៃទៀត។

## ឥរិយាបថភេទមេត្រីដែលមិនសមរម្យ

ព្រះពុទ្ធអង្គក៏ទ្រង់បានពណ៌នានូវផលដែលបុរសចំណាស់ អាចនឹងត្រូវប្រឈម ប្រសិនបើគាត់រៀបការដោយមិនមានការពិចារណាអំពីភាពត្រូវគ្នានៃអាយុរបស់ភាគីម្ខាងទៀតនោះ។ យោងតាមព្រះពុទ្ធអង្គការប្រព្រឹត្តភេទសម្ព័ន្ធដែលគ្មានការទទួលខុសត្រូវ អាចក្លាយទៅជាហេតុនៃសេចក្តីវិនាសដល់ខ្លួនក្នុងទិដ្ឋភាពផ្សេងៗនៃជីវិត។

ប្រជាជាតិទាំងអស់ក្នុងលោក បានកំណត់ច្បាប់យ៉ាងច្បាស់លាស់ទាក់ទងនឹងការរំលោភផ្លូវភេទ។ ក្នុងទីនេះម្តងទៀត ពុទ្ធសាសនាគាំទ្រថាមនុស្សម្នាក់ៗត្រូវតែគោរពនិងធ្វើតាមច្បាប់របស់ប្រទេស ប្រសិនបើច្បាប់ទាំងនោះត្រូវបានធ្វើឡើងសម្រាប់សេចក្តីល្អទូទៅនោះ។

## ១០.បូព៌ា និងបស្ចិមប្រទេស

សេចក្តីខាងក្រោមនេះ ជាសម្រង់ចេញពីសៀវភៅមួយដោយអ្នកនិពន្ធជាតិជប៉ុនដ៏ល្បីល្បាយម្នាក់គឺ លោក **បណ្ឌិត និក្ស៊ូ និវណូ** នៅក្នុងសៀវភៅរបស់លោកមានចំណងជើងថា "**ជីវិតសម្បូរបែប** "។ លោក **បណ្ឌិត និវណូ** សង្កត់ធ្ងន់ជាមួយនឹងបញ្ហាដែលទាក់ទងទៅនឹងសេចក្តីស្នេហានិងអាពាហ៍ពិពាហ៍តាមទស្សនៈទាំងរបស់បូព៌ាប្រទេស និងបស្ចិមប្រទេស។

"នៅក្នុងលោកខាងលិច អាពាហ៍ពិពាហ៍ផ្អែកលើមូលដ្ឋាននៃសេចក្តីស្នេហាមនោសញ្ចេតនា ដែលជាញឹកញាប់ត្រូវបានគេចាត់ទុកជាធម្មជាតិ និងពេលខ្លះជាឧត្តមគតិ។ នៅក្នុងទ្វីបអាស៊ីនាប៉ុន្មានឆ្នាំថ្មីៗនេះ ចំនួននៃយុវវ័យដែលបានបោះបង់អាពាហ៍ពិពាហ៍ ដែលរៀបចំឡើងមានលក្ខណៈជាប្រពៃណី ហើយជ្រើសរើសយកគូស្រករ ដោយការពិចារណាបែបមនោសញ្ចេតនា បាននឹងកំពុងតែរីកធំធាត់ឡើង។ ប៉ុន្តែក្នុងករណីខ្លះ អាពាហ៍ពិពាហ៍មនោសញ្ចេតនានាំទៅរកការបែកបាក់ និងសេចក្តីទុក្ខក្នុងរយៈពេលដ៏ឆាប់មួយ។ ចំណែកឯអាពាហ៍ពិពាហ៍ដែលរៀបចំឡើងតាមប្រពៃណី ជាញឹកញាប់ធ្វើឱ្យគូស្វាមីភរិយា ដែលរស់នៅនិងធ្វើការរួមគ្នាប្រកបដោយសោមនស្ស និងសេចក្តីសុខពិត។

ថ្វីបើមានការពេញចិត្តផ្អែកអារម្មណ៍ក៏ដោយ គេក៏មិនអាចហៅអាពាហ៍ពិពាហ៍បែបមនោសញ្ចេតនាទាំងអស់ ដែលមិនមានលក្ខណៈគ្រប់គ្រាន់ថាជាអាពាហ៍ពិពាហ៍ជោគជ័យបានឡើយ។ ស្នេហាមនោសញ្ចេតនាគឺដូចជាអណ្តាតភ្លើងអុសមានពន្លឺដ៏ចែងចាំងដែលកើតឡើង ហើយឆេះយ៉ាងប្រាកដ ប៉ុន្តែតាំងនៅតែរយៈពេលខ្លីប៉ុណ្ណោះ។ សេចក្តីស្នេហារវាងប្តីនិងប្រពន្ធឆេះឡើងយ៉ាងស្ងប់ស្ងៀម ហើយយឺតៗដូចជាភ្លើងធ្យូងដូច្នោះដែរ។ ជាការពិត ស្នេហាអណ្តាតភ្លើងដ៏ចែងចាំងអាចនឹងជាឧត្តមគតិគាប់ជួនជាទីបំផុតក៏ស្ងប់ស្ងាត់ ហើយពេញដោយភ្លើងនៃស្នេហាពុះកញ្ជ្រោលពេញបន្ទុក ប៉ុន្តែជាញឹកញាប់ អណ្តាតភ្លើងស្នេហាមនោសញ្ចេតនាបែបនេះក៏រលត់ទៅយ៉ាងឆាប់រហ័ស គ្មានបន្សល់ទុកអ្វីក្រៅពីផេះដែលជាមូលដ្ឋានដ៏កំសត់ សម្រាប់ជីវិតអាពាហ៍ពិពាហ៍ ដែលថាបានជោគជ័យនោះសោះឡើយ។

យុវវ័យក្នុងស្នេហា មិនគិតអ្វីក្រៅពីអារម្មណ៍របស់ពួកគេនោះឡើយ ពួកគេមើលឃើញខ្លួនឯងតែក្នុងពន្លឺនៃអារម្មណ៍មួយខណៈនោះប៉ុណ្ណោះ។ អ្វីៗដែលពួកគេគិតនិងធ្វើគឺមនោសញ្ចេតនា ហើយបានផ្តែផ្តាតិចតួចណាស់នៅលើកិច្ចការ ដែលត្រូវអនុវត្តនៃជីវិតជាក់ស្តែង ដែលពួកគេត្រូវតែដឹកនាំក្រោយពីអាពាហ៍ពិពាហ៍នោះ។ ប្រសិនបើគូស្នេហ៍មានសំណាងគ្រប់គ្រាន់ក្នុងការមានបុគ្គលិកលក្ខណៈត្រូវគ្នា មានទស្សនៈជីវិត

ល្អ និងភាពស្រដៀងគ្នា ចេះចែករំលែកផលប្រយោជន៍រីករាយនឹងទំនាក់ទំនងគ្រួសារ ដោយការចុះសម្រុងគ្នាទាំងសងខាងនិងធ្វើឱ្យមានសុវត្ថិភាពផ្នែកហិរញ្ញវត្ថុផងនោះ សូម្បីតែក្រោយពីភាពត្រេកត្រអាលគ្រាដំបូងបានស្រកស្រុតចុះហើយក៏ដោយ ក៏ពួកគេនឹងនៅតែមានមូលដ្ឋានសម្រាប់ជីវិតដ៏ប្រសើរជាមួយគ្នា។ ប្រសិនបើពួកគេមិនមានមង្គលបែបនេះទេពួកគេនឹងត្រូវប្រឈមមុខចំពោះការបរាជ័យផ្នែកអាពាហ៍ពិពាហ៍។

នៅថ្ងៃរៀបមង្គលការនោះ រូបភាពនៃមនោរម្មណ៍ ការរាំរែកពិធីជប់លៀងបានកន្លងផុតទៅ គូស្វាមីភរិយាវ័យក្មេងនោះ នឹងត្រូវរស់នៅជាមួយគ្នា ចែករំលែកអាហារ និងលាតត្រដាងចំពោះគ្នានឹងគ្នានូវគុណវិបត្តិនិងសេចក្ដីល្អរបស់ខ្លួនរៀងៗខ្លួនផងដែរ។ ពួកគេនឹងត្រូវចំណាយពេលវេលាច្រើនជាងពាក់កណ្ដាលជីវិតរបស់ខ្លួន ក្នុងការរស់នៅជាមួយគ្នារាល់ថ្ងៃ។ ការរស់នៅប្រភេទនេះ ធ្វើឱ្យមានការទាមទារដែលខុសគ្នាពីតម្រូវការជាក់ស្ដែងតិចណាស់នៃថ្ងៃរៀបការនិងស្នេហាគ្រាដំបូងនោះ។

ទំនាក់ទំនងគ្រួសារក្លាយជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ណាស់ក្នុងជីវិតអាពាហ៍ពិពាហ៍។ វាចាំបាច់ណាស់ក្នុងការគិតពិចារណាពីបុគ្គលិកលក្ខណៈនៃម្ដាយនិងឪពុករបស់គូស្រករអាពាហ៍ពិពាហ៍ទៅថ្ងៃមុខនោះ។ មានពេលខ្លះ ពួកយុវវ័យគិតថាកម្លាំងនៃសេចក្ដីស្នេហារបស់ពួកគេអាច

នឹងធ្វើឱ្យពួកគេមានជ័យជំនះទៅលើជម្លោះដ៏សន្ធឹកសន្ធាប់ ជាមួយនឹងឧបសគ្គសាច់ថ្លៃ ប៉ុន្តែសេចក្តីនេះមិនមែនពិតទាំងស្រុងនោះទេ។ ជាសរុបមក ភាពរំជើបរំជួលចិត្តគឺជាបញ្ហាមួយដែលមានពេលកំណត់ និងមិនបានចាក់ឫសជ្រៅទៅក្នុងការពិតឡើយ ហើយគេត្រូវតែដាក់កម្រិតក្នុងការសម្របសម្រួលចំពោះតម្រូវការនៃការងារ និងបរិស្ថាន ដើម្បីចងគូស្វាមី-ភរិយាទាំងពីរភ្ជាប់គ្នា ក្នុងភក្តីភាពដ៏យូរលង់នោះ។ សេចក្តីស្នេហាទាំងពីរប្រភេទនេះមានលក្ខណៈខុសគ្នា។ ការច្រឡំស្នេហាមួយនេះថាជាស្នេហាមួយទៀតនាំឱ្យមានបញ្ហាយ៉ាងធ្ងន់ធ្ងរ។

ការគិតឱ្យល្អិតល្អន់ និងមិនប្រកបដោយរាគៈ (នេក្ខម្មវិតក្ក) ចំពោះលក្ខណៈរបស់មនុស្ស ដែលយើងនឹងរៀបការជាមួយ កាត់បន្ថយនូវភាពបរាជ័យដែលនឹងកើតឡើង។ ដើម្បីការពារនូវសេចក្តីរំជើបរំជួលចិត្តពីការបាត់បង់ទៅ ក្រោយពីអាពាហ៍ពិពាហ៍នោះ ការយោគយល់គ្នាទៅវិញទៅមករវាងគូស្វាមីភរិយាមិនអាចខ្វះបានឡើយ។ តែភាគរយនៃជីវិតអាពាហ៍ពិពាហ៍ដែលបានទទួលជោគជ័យ មានចំនួនកាន់តែខ្ពស់ក្នុងចំ-ណោមយុវវ័យ ដែលការជ្រើសរើសរកគូស្រករបស់ខ្លួន ស្របជាមួយនឹងគំនិតឪពុកម្តាយរបស់ខ្លួននោះ។ ដើម្បីរស់នៅប្រកបដោយសេចក្តីសុខស្ងប់នោះ វាជាការចាំបាច់ណាស់ ក្នុងការធ្វើឱ្យជាក់ច្បាស់នូវភាពខុសគ្នារវាងសេចក្តីស្នេហាប្រលោមលោក និងស្នេហាអាពាហ៍ពិពាហ៍" នោះ។

## ១១.ភាពនៅលីវ[៣]

### *តើភាពនៅលីវជាអ្វី?*

ភាពនៅលីវ គឺជាការវៀរចាកពីសកម្មភាពត្រេកត្រអាល ប្រកបដោយកាមគុណ។ មនុស្សមួយចំនួនរិះគន់ពុទ្ធសាសនាដោយនិយាយថា ឱវាទរបស់ព្រះពុទ្ធដើរប្រឆាំងនឹងធម្មជាតិ ហើយពួកគេអះអាងថាជីវិតមានភេទសម្ព័ន្ធ គឺជាធម្មជាតិ ព្រោះហេតុដូច្នេះហើយ វាជាការចាំបាច់ត្រូវតែមានទំនាក់ទំនងផ្លូវភេទ។

ពុទ្ធសាសនាមិនបានប្រឆាំងនឹងភេទសម្ព័ន្ធឡើយ ភេទសម្ព័ន្ធគឺជាភាពត្រេកត្រអាលប្រកបដោយកាមគុណពីធម្មជាតិ ហើយវាជាផ្នែកមួយនៃជីវិតលោកីយ៍យ៉ាងជាក់លាក់។ បុគ្គលអាចនឹងចោទសួរថា តើហេតុអ្វីបានជាព្រះពុទ្ធអង្គគាំទ្រភាពនៅលីវជាសិក្ខាបទ? តើវាមិនមែនអយុត្តិធម៌ ហើយប្រឆាំងនឹងធម្មជាតិទេឬ? ការរក្សានូវភាពនៅលីវសម្រាប់ជាសេចក្តីចម្រើនផ្នែកសតិបញ្ញា មិនមែនជាសិក្ខាបទបែបសាសនាថ្មីថ្មោងមាននៅ

---

៣ , ភាពនៅលីវក្នុងនេះ មិនមែនមានន័យត្រឹមតែការរស់នៅដោយមិនមានការយកប្តីប្រពន្ធដូចន័យធម្មតានោះទេ គឺមានន័យទូលំទូលាយណាស់ បានដល់ការមិនមានទំនាក់ទំនងផ្លូវភេទ ការមិនប្រព្រឹត្តកន្លងនូវសិក្ខាបទទី៣ គឺអព្រហ្មចរិយានេះឯង។

ត្រឹមសម័យពុទ្ធកាលនោះទេ។ ពាហិរសាសនាទាំងអស់ដែលមាននៅក្នុងប្រទេសឥណ្ឌានាសម័យនោះ ក៏បានណែនាំឱ្យមានការប្រតិបត្តិនេះដែរ។ សូម្បីតែសព្វថ្ងៃនេះ អ្នកសាសនាដទៃខ្លះទៀត ដូចជាពួកហិណ្ឌូ និងពួកកាតូលិកក៏ធ្វើការរក្សាសិក្ខាបទនេះជាគោលការណ៍ដែរ។

ពុទ្ធសាសនិកទាំងឡាយ ដែលបានលះបង់ជីវិតលោកីយ៍ដោយស្ម័គ្រចិត្តរក្សានូវសិក្ខាបទនេះ ពីព្រោះពួកគេដឹងយ៉ាងជាក់ច្បាស់នូវការប្រព្រឹត្តទៅនិងភាពរំខានទាំងឡាយដែលចូលមក ប្រសិនបើពួកគេប្តេជ្ញាខ្លួនចំពោះជីវិតនៃមនុស្សដែលមានគ្រួសារ។ ជីវិតអាពាហ៍ពិពាហ៍អាចធ្វើឱ្យរាំងរើប ឬកាត់បន្ថយនូវសេចក្តីចម្រើននូវសតិបញ្ញា កាលបើចំណង់ចំពោះភេទសម្ព័ន្ធ និងសេចក្តីប្រកាន់មាំគ្រប់គ្រងចិត្តហើយចំណង់បាំងបាត់នូវសេចក្តីស្ងប់ និងសេចក្តីបរិសុទ្ធចិត្ត(ចិត្តវិសុទ្ធិ)។

## សារៈសំខាន់នៃភាពនៅលីវ

មនុស្សមាននិន្នាការក្នុងការចោទសួរថា "ប្រសិនបើព្រះពុទ្ធអង្គមិនបានទេសនាប្រឆាំងនឹងជីវិតអាពាហ៍ពិពាហ៍ទេ ហេតុអ្វីបានជាព្រះអង្គគាំទ្រភាពនៅលីវ ថាជាសិក្ខាបទដ៏សំខាន់មួយ បណ្តាសិក្ខាបទទាំងអស់

ដែលត្រូវរក្សា ហើយហេតុអ្វីបានជាព្រះអង្គទូន្មានមនុស្សឱ្យចៀសវាង ភេទសម្ព័ន្ធ និងលះបង់នូវជីវិតជាលោកីយ៍ចោលទៅវិញ?"

បុគ្គលត្រូវចងចាំថា ***នេក្ខម្ម:*** គឺការចេញចាកកាម មិនមែនជាការចាប់បង្ខំទេនៅក្នុងព្រះពុទ្ធសាសនា។ វាមិនមែនជាកាតព្វកិច្ច ដែលត្រូវតែលះបង់ជីវិតជាលោកីយ៍ទាំងស្រុង ដើម្បីប្រតិបត្តិពុទ្ធសាសនានោះទេ។ លោកអ្នកអាចសម្របសម្រួលនូវមាគ៌ាជីវិតរបស់ខ្លួនដោយយោងទៅតាមការយល់ដឹងរបស់លោកអ្នក ដោយការប្រតិបត្តិនូវគោលការណ៍ និងលក្ខណសម្បត្តិសាសនាជាក់លាក់បាន។ លោកអ្នកអាចចម្រើនគោលការណ៍សាសនារបស់ខ្លួន យោងតាមតម្រូវការនៃជីវិតជាគ្រហស្ថបាន។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលលោកអ្នកបានចម្រើន និងសម្រេចនូវបញ្ញាដ៏លើសលប់ ហើយធ្វើឱ្យជាក់ច្បាស់ថាមាគ៌ាជីវិតរបស់គ្រហស្ថមិននាំមកនូវការចម្រើននូវគុណធម៌ ប្រកបដោយសតិបញ្ញាដ៏ក្រៃលែង និងសេចក្តីបរិសុទ្ធចិត្តនោះ លោកអ្នកអាចជ្រើសរើសដើម្បីលះបង់នូវជីវិតជាលោកីយ៍ហើយផ្តោតខ្លាំងទៅលើការចម្រើននូវសតិបញ្ញាបន្ថែមទៀតបាន។

ព្រះពុទ្ធអង្គបានផ្តល់ឱវាទអំពីភាពនៅលីវ ពីព្រោះថាភេទសម្ព័ន្ធ និងអាពាហ៍ពិពាហ៍មិនមែននាំទៅកាន់សន្តិភាព និងចិត្តវិសុទ្ធិគឺសេចក្តីបរិសុទ្ធចិត្តដ៏ក្រៃលែងឡើយ ហើយនេក្ខម្ម:គឺការចេញចាកកាមគុណ គឺចាំ

បាច់ណាស់ ប្រសិនបើបុគ្គលប្រាថ្នាដើម្បីបានសម្រេចនូវការចម្រើនសតិបញ្ញានិងបារមីថ្នាក់ខ្ពស់បំផុតនោះ ។ ប៉ុន្តែការចេញចាកកាមគុណនេះគប្បីកើតឡើងដោយធម្មជាតិ មិនត្រូវកើតឡើងដោយការបង្ខិតបង្ខំឡើយ ។ ការចេញចាកកាមគុណនេះ គប្បីកើតឡើងតាមរយៈការយល់ដឹងយ៉ាងពេញលេញចំពោះកលមាយានៃអត្តភាវៈគឺខ្លួន និងសភាពជាទុក្ខណាមួយនៃសេចក្តីត្រេកត្រអាលប្រកបដោយកាមគុណទាំងអស់ ។

## ភាពនៅលីវនឹងការទទួលខុសត្រូវ -បទពិសោធន៍របស់ព្រះពុទ្ធអង្គ

ព្រះពុទ្ធអង្គបានឆ្លងកាត់ការពិសោធជីវិត ជាលោកីយ៍របស់ព្រះអង្គជាព្រះរាជកុមារជាស្វាមី និងជាបិតាមុនពេលការចេញចាកកាមរបស់ទ្រង់ ហើយព្រះអង្គដឹងច្បាស់នូវអ្វីៗដែលពាក់ព័ន្ធនឹងជីវិតអាពាហ៍ពិពាហ៍ ។ មនុស្សអាចនឹងសួរអំពីនេក្ខម្មៈ គឺការចេញចាកកាមរបស់ព្រះពុទ្ធអង្គដោយនិយាយថាព្រះអង្គជាបុគ្គលអាត្មានិយម និងឃោរឃៅហើយការណ៍នោះមិនយុត្តិធម៌ឡើយ ដែលព្រះអង្គលះបង់ចោលអគ្គមហេសីនិងបុត្រដូច្នេះ ។ តាមការពិត ព្រះពុទ្ធមិនបានលះបង់ចោលគ្រួសាររបស់ព្រះអង្គដោយមិនមានការទទួលខុសត្រូវនោះទេ ។

ព្រះអង្គមិនដែលមានការយល់ខុសណាមួយឡើយ ជាមួយនឹងអគ្គមហេសីរបស់ព្រះអង្គ។ ព្រះអង្គមានសេចក្តីស្រឡាញ់ និងចិត្តជាប់ជំពាក់ចំពោះអគ្គមហេសី និងបុត្ររបស់ព្រះអង្គដូចជាមនុស្សធម្មតាដែរ ប្រហែលជាអាចនឹងមានខ្លាំងជាងផង។ ភាពខុសគ្នានោះគឺថា សេចក្តីស្រ-ឡាញ់របស់ព្រះអង្គ មិនត្រឹមតែជាសេចក្តីស្រឡាញ់ប្រកបដោយភាពអា-ត្មានិយម និងខាងផ្នែករូបកាយប៉ុណ្ណោះទេ ព្រះអង្គមានសេចក្តីក្លាហាននិងបញ្ញា ក្នុងការកាត់ផ្តាច់នូវសេចក្តីស្រឡាញ់ ប្រកបដោយភាពអាត្មានិយម និងបែបមនោរម្មណ៍នោះសម្រាប់ជាមូលហេតុដ៏ល្អ។ ពលីកម្មរបស់ព្រះអង្គត្រូវបានចាត់ទុកជាការលះបង់ដ៏ប្រសើរក្រៃលែង ពីព្រោះព្រះអង្គបានដាក់ចុះនូវតម្រូវការ និងចំណង់ផ្ទាល់ខ្លួនទុកមួយឡែកដើម្បី ***បម្រើមនុស្សជាតិទាំងអស់សម្រាប់គ្រប់ពេលវេលា*** ។

គោលបំណងដ៏ចំបងនៃការចេញចាកកាមរបស់ព្រះអង្គ គឺមិនត្រឹមតែសម្រាប់ជាសេចក្តីសុខ សន្តិភាព និងការរំដោះខ្លួនរបស់ព្រះអង្គផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិទាំងមូល។ ប្រសិនបើព្រះអង្គស្ថិតនៅក្នុងព្រះបរមរាជវាំង សេវាកិច្ចរបស់ព្រះអង្គអាចត្រូវបានកំណត់នៅត្រឹមតែក្រុមគ្រួសារ និងអាណាចក្ររបស់ព្រះអង្គតែប៉ុណ្ណោះ ព្រោះហេតុនោះហើយ ទើបព្រះអង្គសម្រេចព្រះទ័យក្នុងការចេញចោលអ្វីៗគ្រប់យ៉ាង ក្នុងការរក្សាសន្តិភាព និងសេចក្តីបរិសុទ្ធ ដើម្បី

នឹងបានសម្រេចនូវការត្រាស់ដឹង ហើយទើបញ៉ាំងអ្នកដទៃ ដែលទទួលរងទុក្ខនៅក្នុងអវិជ្ជានោះឱ្យត្រាស់ដឹងផងដែរ ។

កិច្ចការមួយបណ្តាកិច្ចការដំបូងបង្អស់របស់ព្រះពុទ្ធអង្គ ក្រោយពេលការត្រាស់ដឹងនោះ គឺត្រឡប់ទៅកាន់ព្រះបរមរាជវាំងរបស់ព្រះអង្គ ដើម្បីញ៉ាំងក្រុមព្រះញាតិវង្សរបស់ព្រះអង្គឱ្យត្រាស់ដឹងផង ។ ជាការពិតកាលដែលបុត្រតូចរបស់ព្រះអង្គ គឺរាហុលកុមារបានសុំនូវកំណប់ទ្រព្យពីព្រះអង្គ ព្រះសម្មាសម្ពុទ្ធបានត្រាស់ថារាហុលគឺជាទាយាទ សម្រាប់ទ្រព្យដ៏មានតម្លៃបំផុត គឺបានដល់កំណប់នៃព្រះធម៌ ។ ក្នុងវិធីនេះព្រះពុទ្ធអង្គបានបម្រើគ្រួសាររបស់ទ្រង់ ហើយព្រះអង្គបានត្រាយផ្លូវសម្រាប់ការរំដោះខ្លួន សន្តិភាព និងសេចក្តីសុខរបស់ពួកព្រះញាតិវង្សទាំងឡាយ ។ ដូច្នេះ គ្មាននរណាម្នាក់អាចនិយាយថា ព្រះពុទ្ធជាបិតាឃោរឃៅ ឬអាត្មានិយមឡើយ ។ តាមការពិត ព្រះអង្គមានករុណា និងការបូជាខ្លួនដ៏យ៉ាងក្រៃលែងជាងនរណាៗទៀតទាំងអស់ ។ ដោយការចម្រើននូវសតិបញ្ញាជាន់ខ្ពស់នោះ ព្រះសម្មាសម្ពុទ្ធបានដឹងថាអាពាហ៍ពិពាហ៍គឺជាការវិវត្តជាបណ្តោះអាសន្នទេ ចំណែកឯការត្រាស់ដឹងទើបជាអមតៈ ហើយសម្រាប់ជាសេចក្តីសុខដល់មនុស្សជាតិទាំងមូល ។

ព្រឹត្តការណ៍ដ៏សំខាន់មួយទៀតនោះ គឺថាព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបថាអគ្គមហេសី និងបុត្ររបស់ព្រះអង្គ នឹងមិនអត់ឃ្លានឡើយក្នុងកាលដែលអវត្តមានរបស់ព្រះអង្គនោះ។ នៅសម័យពុទ្ធកាលត្រូវបានគេចាត់ទុកជាការធម្មតា និងប្រកបដោយកិត្តិយសមែនពិតសម្រាប់បុរសវ័យក្មេងក្នុងការចូលនិវត្តន៍ពីជីវិតជាយរាវាស។ សមាជិកដទៃទៀតនៃក្រុមគ្រួសារអាចនឹងរំពឹងនូវការពឹងពាក់របស់ព្រះអង្គប្រកបដោយឆន្ទៈ។ នៅពេលដែលព្រះអង្គបានសម្រេចការត្រាស់ដឹង ហើយព្រះអង្គអាចនឹងផ្តល់ឱ្យពួកក្រុមញាតិនូវអ្វី១ ដែលគ្មានឪពុកណាអាចឱ្យបាននោះ គឺសេរីភាពពីទាសភាពរបស់តណ្ហា។

## ១២_សេចក្ដីសង្ខេប

អាពាហ៍ពិពាហ៍ គឺភាពជាដៃគូនៃបុគ្គលពីរនាក់ ហើយភាពជាដៃគូនេះត្រូវធ្វើជីវិតឱ្យមានតម្លៃ និងត្រូវលើកកំពស់នៃតម្លៃជីវិតឡើងនៅពេលដែលវាអនុញ្ញាតឱ្យបុគ្គលិកភាពដែលពាក់ព័ន្ធឱ្យធំធាត់ឡើង។ អាពាហ៍ពិពាហ៍ជាច្រើនបរាជ័យ ពីព្រោះដៃគូម្នាក់ព្យាយាម "លេប" ដៃគូម្នាក់ទៀត ឬនៅពេលម្នាក់ត្រូវការសេរីភាពដ៏ពេញលេញនោះ។ បើយោងតាមពុទ្ធសាសនា អាពាហ៍ពិពាហ៍មានន័យថាការយោគយល់គ្នា និងការគោរពនូវជំនឿ និងភាពជាឯកជននៃគ្នានឹងគ្នា។ អាពាហ៍ពិពាហ៍ដែលប្រកបដោយជោគជ័យ គឺតែងតែជាផ្លូវពីរជានិច្ចគឺ "*ដែលមានរាងកោង និង រដិបរដុប*" វាមានការលំបាក ប៉ុន្តែវាតែងតែជាផ្លូវទៅវិញទៅមក។

ជួនកាលយុវវ័យក្នុងប្រទេសនេះ ឬកន្លែងផ្សេងៗទៀតគិតថា "ទស្សនៈដែលមានលំនាំចាស់" គឺមិនមានការពាក់ព័ន្ធទៅនឹងសង្គមទំនើបឡើយ។ គួរគប្បីរំលឹកដល់ពួកគេថា មានសច្ចភាពជាអមតៈខ្លះដែលមិនអាចក្លាយទៅជាហួសសម័យបានឡើយ អ្វីដែលជាសច្ចភាពនាសម័យពុទ្ធកាល ស្ថិតនៅតែជាសច្ចភាពរហូតដល់សព្វថ្ងៃនេះ។

ដែលហៅថាទស្សនៈទំនើប ដែលយើងទទួលបានតាមរយៈកម្មវិធីទូរទស្សន៍ដ៏ឆើតឆាយយ៉ាងខ្ពស់ត្រដែតនោះ មិនបានបង្ហាញអំពីផ្លូវដែលមនុស្សមានសុជីវធម៌ភាគច្រើន នៅក្នុងលោកខាងលិចគិត និងប្រព្រឹត្តឡើយ។ វាមាន"ការលាក់លៀមច្រើន" យ៉ាងទូលំទូលាយនៃគូស្វាមីភរិយាមានសុជីវធម៌ដែលជាអ្នកសាសនាយ៉ាងជ្រាលជ្រៅ និងជាអ្នក "អភិរក្សនិយម" អំពីអាពាហ៍ពិពាហ៍ដូចជាគូស្វាមីភរិយានៅបូព៌ាប្រទេសដែរ។ ពួកគេមិនបានប្រព្រឹត្តក្នុងឥរិយាបថ ដែលបណ្ដុំប្រព័ន្ធផ្សព្វផ្សាយបានគូរវាសឡើយ។ មិនមែនមនុស្សទាំងអស់នៅក្នុងបស្ចិមប្រទេសធ្វើការលែងលះគ្នា ឬការយកកូនចេញ ក្រោយពីមានជម្លោះដំបូងនោះឡើយ។

មនុស្សដែលមានសុជីវធម៌ពាសពេញពិភពលោកទាំងអស់ ក៏ដូចគ្នា ពួកគេមិនមែនជាបុគ្គលអាត្មានិយមឡើយ ហើយពួកគេមើលថែយ៉ាងជ្រាលជ្រៅចំពោះបុគ្គលដែលពួកគេស្រឡាញ់។ ពួកគេបានធ្វើការបូជាដ៏សម្បើម និងបង្កើតសេចក្ដីស្រឡាញ់ ការយោគយល់គ្នាដើម្បីធានានូវអាពាហ៍ពិពាហ៍មួយ ប្រកបដោយស្ថិរភាព និងសេចក្ដីសុខ។ ដូច្នេះហើយប្រសិនបើលោកអ្នកចង់ត្រាប់តាមលោកខាងលិច ចូរត្រាប់តាម "ការលាក់លៀមភាគច្រើន" នោះ ពួកគេមិនមានអ្វីខុសប្លែកគ្នាពី

អ្នកជិតខាង ប្រកបដោយសុជីវធម៌ ដែលរស់នៅជិតនឹងលោកអ្នកឡើយ ។

ពួកយុវវ័យទាំងឡាយ ត្រូវតែស្តាប់នូវរបៀមច្បងរបស់ខ្លួនផងដែរ ពីព្រោះការយល់ដឹងរបស់ខ្លួន អំពីរឿងជីវិតអាពាហ៍ពិពាហ៍មិនទាន់គ្រប់គ្រាន់នោះទេ ។ ពួកគេពុំគួរគប្បីធ្វើសេចក្តីសន្និដ្ឋានយ៉ាងប្រ-ញាប់ប្រញាល់នោះពេកទេ ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍និងការលែងលះនោះ ពួកគេត្រូវតែមានសេចក្តីអត់ធន់ (ខន្តី) និងការយោគយល់គ្នាទៅវិញទៅមកច្រើនទើបប្រសើរ បើមិនដូច្នោះទេ ជីវិតរបស់ពួកគេអាចក្លាយជាទុក្ខវេទនា និងប្រកបដោយបញ្ហា ។ សេចក្តីអត់ធន់ ខន្តីនិងការយោគយល់គ្នា គឺជាក្រមវិន័យដ៏មានសារៈសំខាន់ដែលត្រូវរក្សានិងអនុវត្តដោយមនុស្សដែលស្ថិតនៅក្នុងជីវិតអាពាហ៍ពិពាហ៍ទាំងអស់គ្នា ។ អារម្មណ៍នៃសុវត្ថិភាព និងសេចក្តីសន្តោសកើតមកពីការយោគយល់គ្នាទៅវិញទៅមក ដែលជារឿងដ៏សម្ងាត់ និងសំខាន់នៃសុភមង្គលក្នុងខ្សែជីវិតអាពាហ៍ពិពាហ៍ ។

# ក្រមសីលធម៌

## ១-សង្គម និងក្រមសីលធម៌

កត្តាដ៏សំខាន់បំផុតនៃការកែប្រែព្រះពុទ្ធសាសនា គឺតែងតែពាក់ព័ន្ធទៅនឹងសង្គម និងក្រមសីលធម៌ជានិច្ច។ ក្រមសីលធម៌នោះឯង គឺជាក្រមសីលធម៌ល្អឥតខ្ចោះបំផុតមួយ ដែលពិភពលោកធ្លាប់បានស្គាល់។ នៅត្រង់ចំណុចនេះ សក្ខីភាពទាំងអស់ ទាំងមកពីក្រុមសត្រូវ ទាំងមកពីក្រុមមិត្តបានយល់ស្របគ្នា ទាំងទស្សនវិទូទាំងឡាយ ពួកអ្នកផ្សាយសាសនា អ្នកបរមត្ថវិទ្យាដ៏ល្អិតសុខុម វិវាទី[៤] ទាំងឡាយអាចនឹងមានប្រាកដឡើង ប៉ុន្តែតើនៅទីណាទើបយើងអាចរកអវតារនៃក្តីស្រឡាញ់ ជាក្តីស្រឡាញ់ដែលមិនមានការបែងចែកវណ្ណៈ ជំនឿសាសនា ពណ៌សម្បុរជាក្តីស្រឡាញ់ដែលហួសពីសមានចិត្តរបស់មនុស្សជាតិ ពោរពេញដោយសេចក្តីករុណាចំពោះសព្វសត្វទាំងអស់ ជាក្តីស្រឡាញ់ដែលតំណាងឱ្យសិក្ខាបទមេត្តាសាកលនិងអហិង្សា។ (លោកសាស្ត្រាចារ ***ម៉ាក្ស មូល្ល័រ*** ពុទ្ធសាសនិកបណ្ឌិត ជាតិអាល្លឺម៉ង់)។

៤ , អ្នកដែលចូលចិត្តជជែក ពិភាក្សា ដោយការចង់ឈ្នះ ចង់ចាញ់គ្នាទៅវិញទៅមក។

## ***២-សីលធម៌ត្រូវផ្អែកលើសេរីភាព***

សីលធម៌ពុទ្ធសាសនា ត្រូវផ្អែកលើសេរីភាព ដូចជាការរីកចម្រើននៃបុគ្គលម្នាក់ៗ ដូច្នេះហើយសីលធម៌នេះមានទំនាក់ទំនងគ្នា។ ជាការពិតវាមិនអាចមានគោលការណ៍អភិសមាចារណាមួយឡើយ ប្រសិនបើមានការដាក់កំហិត ឬការកំណត់ពីស្ថាប័នខាងក្រៅខ្លួននោះ។ ( លោក ***អនគរិក ប៊ី គោវិន្ទ*** អ្នកប្រាជ្ញពុទ្ធសាសនិកជាតិអាល្លឺម៉ង់)

## ៣-វិជ្ជា និងសីលធម៌

នៅក្នុងពុទ្ធសាសនាអាចនឹងមិនមានសីលធម៌ពិតប្រាកដឡើយ បើគ្មានវិជ្ជា (បញ្ញា) ហើយក៏គ្មានវិជ្ជាពិតដែរ បើគ្មានសីលធម៌ដែរនោះ[៥] គឺកត្តាទាំងពីរត្រូវផ្សារភ្ជាប់គ្នា ប្រៀបដូចជាកំដៅនិងពន្លឺនៅក្នុងអណ្តាតភ្លើងដូច្នេះដែរ។ អ្វីដែលបង្កបង្កើតនូវ "ពុទ្ធិ" មិនមែនត្រឹមតែវិជ្ជា គឺការត្រាស់ដឹងប៉ុណ្ណោះទេ ប៉ុន្តែគឺមនុស្សធម៌ទៀត។ ចិត្តដែលមានឧត្តមភាពផ្នែកសីលធម៌ គឺជាខ្លឹមសារយ៉ាងពិតប្រាកដរបស់ "ពុទ្ធិ"។ (ភិក្ខុ ***ធម្មបាល*** បណ្ឌិតពុទ្ធសាសនិកជាតិណេឌីឡេនដ៍)។

---

៥ ,ទាក់ទងនឹងរឿងសីល និងបញ្ញានេះ អ្នកបកប្រែក៏សូមបន្ថែមសេចក្តី ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង នៅក្នុងសោណទណ្ឌសូត្រ(ទីឃនិកាយ)ថា អង្គរបស់មនុស្សទាំងឡាយ៥យ៉ាង ពោលគឺពណ៌សម្បុរ១ ការចេះចាំមន្ត ស្ទាត់ជំនាញក្នុងសិល្បសាស្ត្រផ្សេងៗ១ ជាតិ១ បរិបូណ៌ដោយសីល១ និងមានបញ្ញា១ នោះ គេអាចលុបចោលអង្គ៣ខាងដើមបាន ប៉ុន្តែអង្គ២ខាងចុងមិនអាចនឹងលុបណាមួយបានឡើយ។ ពីព្រោះថាអង្គទាំងពីរនេះ ត្រូវពឹងអាស្រ័យគ្នាទៅវិញទៅមក ប្រាជ្ញារមែងជម្រះសីលឱ្យបរិសុទ្ធ សីលទៀតសោតក៏រមែងជម្រះប្រាជ្ញាឱ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញានៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ។ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីលដែរ ឯសីលនិងប្រាជ្ញាប្រាកដជាគុណធម៌ដ៏ប្រសើរក្នុងលោក។ បុគ្គលលាងដៃដោយដៃក្តី លាងជើងដោយជើងក្តី សេចក្តីនេះមានឧបមាយ៉ាងណា ក៏មានឧបមេយ្យដូចជាប្រាជ្ញារមែងជម្រះសីលឱ្យបរិសុទ្ធ សីលសោតក៏រមែងជម្រះប្រាជ្ញាឱ្យបរិសុទ្ធដូច្នេះដែរ។

# ចប់ដោយបរិបូណ៌

## សៀវភៅដែលបានបោះពុម្ពហើយ

-អភិសមាចារពុទ្ធសាសនា ក្នុងជីវិតប្រចាំថ្ងៃ

## សៀវភៅបំរុងនឹងបោះពុម្ពក្នុងពេលឆាប់ៗនេះ

-ជំនួយបញ្ញា ទ្រឹស្តីបដិច្ចសមុប្បាទធម៌

-វិសុទ្ធិមគ្គប្រែ